## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

### របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងឥណទានខ្នាតតូច និង មធ្យម

កម្មសិក្សាពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ហ៊ឹម សីហា**

**ហ៊ាង លីដា**

សាស្ត្រាចារ្យណែនាំ

លោក **ជា សែម**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# មាតិកា


បញ្ជីតារាង ..... vii
បញ្ជីរូប ..... vii
បញ្ជីដ្យាក្រាម ..... vii
បញ្ជីឧបសម្ព័ន្ធ ..... viii


## សេចក្តីផ្តើម


១. លំនាំដើម ..... ១
២. ចំណោទបញ្ហា ..... ២
៣. គោលការនៃការស្រាវជ្រាវ ..... ២
៤. វិធីសាស្រ្តនៃការស្រាវជ្រាវ ..... ២
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤
៧. គម្រោងនៃការស្រាវជ្រាវ ..... ៤


## ជំពូកទី ១
## រំលឹកទ្រឹស្តី


១.១ លក្ខណៈទូទៅនៃគ្រឹស្ថានមីក្រូហិរញ្ញវត្ថុ ..... ៦
១.១.១. ប្រវត្តិនៃការកកើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ..... ៦
១.១.២. និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៨
១.១.៣. គោលបំណងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៩
១.១.៤. តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៩
១.២ លក្ខណៈទូទៅរបស់ឥណទាន ..... ១០
១.២.១. និយមន័យឥណទាន ..... ១០
១.២.២. ប្រភេទនៃឥណទាន ..... ១១
១.២.២.១. ឥណទានទោល ..... ១១
១.២.២.២. ឥណទានក្រុម ..... ១១
១.២.៣. អត្ថប្រយោជន៍ឥណទាន ..... ១១
១.២.៣.១. សម្រាប់អតិថិជន ..... ១១
១.២.៣.២. សម្រាប់អាជីវកម្ម ..... ១២
១.២.៣.៣. សម្រាប់ធនាគារ ..... ១២
១.២.៣.៤. សម្រាប់សេដ្ឋកិច្ច ..... ១២
១.២.៣.៥. សម្រាប់សង្គម ..... ១២
២.២.៤. គ្រោះថ្នាក់ក្នុងការប្រើឥណទាន ..... ១៣
២.២.៤.១. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់ ..... ១៣

២.២.៤.២. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម ........................ ១៣
១.៣. ការគ្រប់គ្រងឥណទាន ........................ ១៣
១.៣.១. គោលដៅរបស់អ្នកគ្រប់គ្រងឥណទាន ........................ ១៣
១.៣.១.១. បង្កើនប្រាក់ចំណូលពីការលក់ ........................ ១៤
១.៣.១.២. ការត្រួតពិនិត្យលើបរិមាណជំពាក់ ........................ ១៤
១.៣.១.៣. ពិនិត្យសោហ៊ុយប្រតិបត្តិការ និងចំនាយ ........................ ១៤
១.៣.១.៤. កាត់បន្ថយចំនាយលើការប្រមូល និងបំណុលពិបាកទារ ........................ ១៤
១.៣.១.៥. បង្កើតគោលនយោបាយឥណទាន និងការប្រមូល ........................ ១៥
១.៣.១.៦. បណ្តុះបណ្តាល និងត្រួតពិនិត្យនិយោជិក ........................ ១៥
១.៣.១.៧. រក្សាទំនាក់ទំនងល្អជាមួយអតិថិជន ........................ ១៥
១.៣.២. និតិវិធីនៃការផ្តល់ឥណទាន ........................ ១៥
១.៤. ដំណើរនៃការគ្រប់គ្រង់ឥណទាន ........................ ១៦
១.៤.១. ការលើកទឹកចិត្ត ........................ ១៦
១.៤.២. ការពិនិត្យលើសំណើរពាក្យសុំលើកដំបូង ........................ ១៦
១.៤.៣. ការស៊ើបអង្កេតឥណទាន ........................ ១៦
១.៤.៤. ការសម្រេចផ្តល់ឥណទាន ........................ ១៦
១.៤.៥. ការត្រួតពិនិត្យគណនី ........................ ១៧
១.៤.៦. ការប្រមូល ........................ ១៧
១.៥. ការវាយតម្លៃក្នុងការផ្តល់ឥណទាន ........................ ១៧
១.៥.១. ចរិកលក្ខណៈ ........................ ១៧
១.៥.២. សមត្ថភាព ........................ ១៨
១.៥.៣. ដើមទុន ........................ ១៨
១.៥.៤. វត្ថុបញ្ចាំ ........................ ១៨
១.៥.៥. លក្ខខណ្ឌ ........................ ១៨
១.៥.៦. សុភវិនិច្ឆ័យ ........................ ១៩
១.៦. ហានិភ័យឥណទាន ........................ ១៩
១.៦.១. និយមន័យ ........................ ១៩
១.៦.២. មូលហេតុដែលនាំអោយមានហានិភ័យឥណទាន ........................ ១៩
១.៦.២.១. កត្តាអតិថិជន ........................ ១៩
១.៦.២.២. កត្តាធនាគារ ........................ ២០
១.៦.២.៣. កត្តាសេដ្ឋកិច្ច សង្គម និងគ្រោះធម្មជាតិ ........................ ២០
១.៦.៣. យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យឥណទាន ........................ ២០
១.៦.៣.១. វាយតម្លៃអតិថិជនអោយបានត្រឹមត្រូវ ........................ ២០

១.៦.៣.២. ពង្រឹងសមត្ថភាពបុគ្គលិកឲ្យមានប្រសិទ្ធភាព....២១
១.៧. ដំណោះស្រាយបំណុលមានបញ្ហា ....២១
១.៧.១. វិធានការទប់ស្កាត់បំណុលមានបញ្ហា.... ២២
១.៧.២. ការដោះស្រាយបំណុលមានបញ្ហា .... ២២

## ជំពូកទី ២

## ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

២.១. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ....២៤
២.២. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា....២៥
២.៣. អត្តសញ្ញាណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ....២៥
២.៣.១. រូបសញ្ញា....២៥
២.៣.២. អត្ថន័យនៃរូបសញ្ញា....២៦
២.៤. ទីតាំងរបស់គ្រឹះស្ថានហិរញ្ញវត្ថុ អេ អឹម ខេ ....២៧
២.៤.១. ទីតាំងសាខាទូទាំង ២៥ខេត្ត-ក្រុង....២៧
២.៤.២. ទីតាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ....២៨
២.៥. ភាគហ៊ុនិក ដើមទុន និងប្រភពហិរញ្ញវត្ថុ....២៩
២.៥.១. ភាគហ៊ុនិក ដើមទុន....២៩
២.៥.២. ដៃគូពាណិជ្ជកម្ម....៣២
២.៦. ទស្សនៈវិស័យ បេសកកម្ម និងវប្បធម៌រូម .... ៣៣
២.៦.១. ទស្សនៈវិស័យ .... ៣៣
២.៦.២. បេសកកម្ម.... ៣៣
២.៦.៣. វប្បធម៌រូម .... ៣៣
២.៧. រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា.... ៣៤
២.៨. ផលិតផល និងសេវាកម្មទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ....៣៥

## ជំពូកទី ៣

## ឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា

៣.១. ទីផ្សារគោលដៅសម្រាប់ឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យម .... ៣៦
៣.២. ឥណទានខ្នាតតូច និងខ្នាតមធ្យម....៣៦
៣.២.១. ផលិតផលឥណទានខ្នាតតូច ....៣៦
៣.២.១.១. ទំហំឥណទាន....៣៦
៣.២.២. ផលិតផលឥណទានខ្នាតមធ្យម ....៣៧
៣.២.២.១. ទំហំឥណទាន....៣៧
៣.២.២.២. ការកំណត់ថ្លៃ....៣៧

ក.អត្រាការប្រាក់ ....................................................................................................... ៣៧
ខ. រយៈពេលខ្ចី .......................................................................................................... ៣៨
៣.៣. ការកំណត់ទំហំឥណទាន និងថ្លៃសេវា......................................................................... ៣៨
៣.៣.១. ការកំណត់ទំហំឥណទាន ........................................................................................ ៣៨
៣.៣.២. ថ្លៃសេវា ............................................................................................................. ៣៨
៣.៤. ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ..................................................................... ៣៨
៣.៤.១. ការវាយតម្លៃក្នុងការផ្តល់ឥណទាន............................................................................ ៣៨
៣.៤.១.១. អត្តចរិករបស់អតិថិជន ...................................................................................... ៣៨
៣.៤.១.២. ដើមទុន .......................................................................................................... ៣៨
៣.៤.១.៣.សមត្ថភាពសង ................................................................................................... ៣៩
៣.៤.១.៤. ទ្រព្យធានា ....................................................................................................... ៣៩
៣.៤.១.៥. លក្ខខណ្ឌ.......................................................................................................... ៣៩
៣.៤.២. នីតិវិធីក្នុងការផ្តល់ឥណទាន...................................................................................... ៣៩
៣.៤.២.១. ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់ .......................................................................... ៣៩
៣.៤.២.២. ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន ............... ៣៩
៣.៤.២.៣. ការរៀបចំឯកសារខ្ចីប្រាក់ ................................................................................... ៤០
៣.៤.២.៤. ការអនុមត័ឥណទាន........................................................................................... ៤០
៣.៤.២.៥. ការរៀបចំកិច្ចសន្យា............................................................................................ ៤០
៣.៤.២.៦. ការបញ្ចេញឥណទាន .......................................................................................... ៤១
៣.៤.៣. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន................................................................................... ៤១
៣.៤.៤. ការសងត្រលប់មកវិញនៃឥណទាន ............................................................................. ៤២
៣.៤.៤.១. ការគណនាការប្រាក់............................................................................................ ៤២
៣.៤.៤.២. របៀបសងប្រាក់ .................................................................................................. ៤២
៣.៤.៤.៣. ការសងត្រលប់មកវិញនៃឥណទាន......................................................................... ៤៤
៣.៤.៤.៤. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ.............................................................. ៤៥
៣.៤.៤.៥. ការផ្តល់ឥណទានបន្ថែម ...................................................................................... ៤៥
៣.៤.៥. ការខកខានសង និងការពិន័យ .................................................................................. ៤៥
៣.៤.៥.១. ការខកខានសង ................................................................................................. ៤៥
៣.៤.៥.២. ការពិន័យ.......................................................................................................... ៤៥
៣.៤.៦. ការធ្វើចំណាតថ្នាក់ឥណទាន និងសំវិធានធន.............................................................. ៤៦
៣.៤.៧. ហានិភ័យឥណទាន ................................................................................................ ៤៦
៣.៤.៧.១. និយមន័យហានិភ័យឥណទាន ............................................................................... ៤៦
៣.៤.៧.២. មូលហេតុនៃហានិភ័យឥណទាន............................................................................. ៤៦

៣.៤.៧.៣. វិធីសាស្ត្រកាត់បន្ថយហានិភ័យឥណទាន ..... ៤៨
៣.៤.៧.៤. វិធីសាស្ត្រដោះស្រាយបំណុលមានបញ្ហា..... ៤៩
៣.៤.៧.៥. ការវាស់វែងអត្រាហានិភ័យឥណទាន ..... ៥០
ក. អត្រាហានិភ័យឥណទាន ..... ៥០
ខ. អត្រានៃការសងត្រលប់មកវិញ ..... ៥០
គ. បំណុលលុបចេញពីបញ្ជី..... ៥១
៣.៥. លទ្ធផលឥណទាននៃការស្រាវជ្រាវ ..... ៥២
៣.៥.១. សមតុល្យឥណទានសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ចាប់ពីឆ្នាំ២០១៤-២០១៦ ..... ៥២
៣.៥.២. ឥណទានដែលបានលុបចេញពីបញ្ជី..... ៥៣
៣.៦. ការវិភាគ SWOT ..... ៥៣
៣.៦.១. ចំណុចខ្លាំង ..... ៥៣
៣.៦.២. ចំណុចខ្សោយ ..... ៥៤
៣.៦.៣. ឱកាស ..... ៥៤
៣.៦.៤. ការគំរាមគំហែង..... ៥៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..... ៥៥
២. ការផ្តល់អនុសាសន៍ ..... ៥៦

**ឯកសារយោង**

# បញ្ជីតារាង

តារាងទី១៖ របៀបសងប្រាក់........................................................................................................៤២
តារាងទី២៖ តារាងបង្ហាញពីបបម្រែបម្រួលនៃទំហំឥណទាន ....................................................៥០
តារាងទី៣៖ តារាងបង្ហាញពីចំនួនអតិថិជនមានការកើនឡើងជាលំដាប់....................................៥១

# បញ្ជីរូបភាព


រូបភាពទី១៖ រូបសញ្ញា ........................................................................................... ២៤
រូបភាពទី២៖ ទីតាំងសាខាទូទាំង២៥ខេត្ត-ក្រុង ............................................................ ២៦
រូបភាពទី៣៖ ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ .............................................. ២៧
រូបភាពទី៤៖ ដៃគូពាណិជ្ជកម្ម ................................................................................ ៣១

# បញ្ជីដ្យាក្រាម

ដ្យាក្រាមទី១៖ បង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចោញ ................................ ៥០
ដ្យាក្រាមទី២៖ បង្ហាញពីចំនួនអតិថិជនមានការកើនឡើងជាលំដាប់.......................................... ៥១

# សេចក្ដីផ្ដើម

## ១. លំនាំដើម

ការរីកចម្រើនរបស់ប្រទេសមួយ វាអាស្រ័យទៅលើស្ថានភាពនយោបាយ សន្តិសុខសង្គម និងកំណើននៃអ្នកវិនិយោគបរទេស និងជនជាតិខ្លួន ។ ជាក់ស្ដែងក្នុងប្រទេសកម្ពុជាយើងនាពេលចុងក្រោយនេះ ដោយសារតែស្ថេរភាពនយោបាយ សន្តិសុខសង្គម និងកំណើនអ្នកវិនិយោគ ធ្វើឲ្យប្រទេសកម្ពុជាមានការរីកចម្រើន ជាពិសេស គឺវិស័យធនាគារដែលក្នុងនោះមានធនាគារពាណិជ្ជ ធនាគារឯកទេស មីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតូចៗ ជាច្រើនកំពុងតែរីកដុះដាលជាបន្តបន្ទាប់។

ដើម្បីធ្វើការវិនិយោគ ដើមទុនគឺជាកត្តាចំបងដ៏សំខាន់ ដែលអ្នកជំនួញទាំងអស់ត្រូវការដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន និង បំពេញនូវតម្រូវការក្នុងសង្គមផងដែរ ។ ដូចនេះបានជាធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនខិតខំពង្រីក និងបង្កើតនូវសេវាកម្មផ្សេងៗ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អតិថិជន ។

ប្រព័ន្ធហិរញ្ញវត្ថុ គឺជាចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ។ ការប្រើប្រាស់ទុន គឺជាការផ្ដល់ផ្លែផ្កាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចទាំងមូល។ ស្របពេលជាមួយគ្នានេះប្រព័ន្ធធនាគារ ស្ថាប័ន ក្រុមហ៊ុន និង សហគ្រាសមានការកើនឡើង ពិសេសសហគ្រាសធុនតូច និងមធ្យម ដែលធ្វើឲ្យវិស័យហិរញ្ញវត្ថុមានការរីកចម្រើន ។

ទន្ទឹមនិងវិស័យមីក្រូហិរញ្ញវត្ថុ នៅប្រទេសកម្ពុជាយើងកំពុងតែមានការរីកចម្រើន វាក៏ជាវិស័យមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយវិស័យផ្សេងៗទៀតនៅក្នុងសង្គមនៅពេលបច្ចុប្បន្នដែរ វាមានសារៈសំខាន់សម្រាប់ផ្ដល់ឥណទាន ដល់អ្នកវិនិយោគ ទាំងក្នុងស្រុក និងក្រៅស្រុកនៅពេលដែលមានការជួបនូវឱនភាព ក្នុងការធ្វើអាជីវកម្មរបស់ពួកគេ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ ។

ជាការពិតណាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់មូនធន ឬសេវាឥណទាន សម្រាប់ឲ្យប្រជាពលរដ្ឋយកទៅធ្វើជាដើមទុន ដើម្បីប្រកបអាជីវកម្មចិញ្ចឹមជីវិត និងពង្រីកមុខរបរឲ្យកាន់តែរីកលូតលាស់ឡើងថែមមួយកម្រិតទៀត ទៅតាមអ្វីដែលអតិថិជនចង់បាន។ ដើម្បីឲ្យអតិថិជនមានការយល់ដឹងកាន់តែច្បាស់នោះ ខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏បានតម្រូវឲ្យបុគ្គលិកចុះធ្វើការផ្សព្វផ្សាយ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងពីសេវាកម្មរបស់ស្ថាប័ន និងចេះប្រើប្រាស់សេវាឥណទាន។ ហេតុដូច្នេះហើយបានជាស្ថាប័ននីមួយៗ ខិតខំប្រឹងប្រែងបញ្ចេញនូវលទ្ធ

ភាពរបស់ខ្លួនក្នុងការទាក់ទាញអតិថិជន ឲ្យទទួលបាននូវសេវាកម្មពីស្ថាប័នរបស់យើង។

ការផ្តល់ឥណទាន គឺជាសេវាកម្មហិរញ្ញវត្ថុ ដែលសំខាន់បំផុតក្នុងការបង្កើនប្រាក់ចំណូលដល់ស្ថាប័ន ជាពិសេសទៅលើទីផ្សារប្រកួតប្រជែងដែលមាននៅក្នុងប្រទេសយើង។ ដូចនេះបានជានាពេលបច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ខិតខំប្រឹងប្រែងផ្តល់ឥណទាន យ៉ាងសកម្មដល់អតិថិជន។ មិនតែប៉ុណ្ណោះគ្រឹះស្ថានបានយកចិត្តទុកដាក់ដល់អតិថិជន និងពង្រឹងដល់សមត្ថភាពបុគ្គលិកឲ្យកាន់តែល្អថែមទៀតដើម្បីឲ្យអតិថិជនមានការពេញចិត្តមកលើគ្រឹះស្ថានរបស់ខ្លួន។

## ២. ចំណោទបញ្ហា

ដើម្បីទទួលបានជោគជ័យ នៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ខិតខំប្រឹងប្រែងផ្សព្វផ្សាយនូវកម្មវិធីឥណទានរបស់ខ្លួន ក្នុងការប្រកួតប្រជែងជាមួយដៃគូជាច្រើនដែលមានក្នុងប្រទេស។ ដូចនេះតើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមរបស់ខ្លួនបែបណា ទើបទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដើម្បីសិក្សាពីប្រសិទ្ធភាពនៃការផ្តល់ឥណទានខ្នាតតូច និងមធ្យមដើម្បីជួយលើកកំពស់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។

-សិក្សាពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

-សិក្សាពីទំហំ និងរយៈពេលឥណទាន

-សិក្សាពីអត្រាការប្រាក់ និងការគណនាការប្រាក់

-សិក្សាពីការត្រួតពិនិត្យ និងការតាមដានឥណទាន

-សិក្សាពីគោលការណ៍ និងលក្ខខណ្ឌនៃការផ្តល់ឥណទាន

-សិក្សាពីនីតិវិធី និងដំណើរការនៃការផ្តល់ឥណទាន

-សិក្សាពីហានិភ័យឥណទាន

-សិក្សាពីផលិតផលឥណទានរបស់ធនាគារ អេ អឹម ខេ

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវលើប្រធានបទការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គឺក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវតាមប្រភពទិន្នន័យពីរគឺប្រភពទិន្នន័យចំបង និងទិន្នន័យបន្ទាបន្សំ។

**ក. ទិន្នន័យចំបង** ( Primary Data )

ទិន្នន័យប្រភេទនេះ គឺជាព័ត៌មានដែលចាត់ទុកថាសំខាន់ ហើយយើងទទួលបានតាមរយៈការសាកសួរផ្ទាល់ជាមួយលោកប្រធានគ្រប់គ្រងសាខា ប្រធានមន្ត្រីឥណទាន បុគ្គលិកទាំងឡាយផ្នែកឥណទាន និងបុគ្គលិកបម្រើក្នុងនាយកដ្ឋានហិរញ្ញវត្ថុ និងការបង្កើតជាកម្រងសំណួរ ដែលពាក់ព័ន្ធនឹងប្រធានបទដើម្បីទទួលបាននូវព័ត៌មានគ្រប់គ្រាន់ជាព័ត៌មានពិត និងមានអត្ថន័យច្បាស់លាស់។ ព្រមទាំងធ្វើការអង្កេតលើការអនុវត្តន៍ជាក់ស្តែង ក្នុងដំណើរការប្រតិបត្តិការឥណទាននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

**ខ. ទិន្នន័យបន្ទាប់បន្សំ** (Secondary Data )

ទិន្នន័យបន្ទាប់បន្សំ គឺជាទិន្នន័យមួយប្រភេទទៀត ដែលទទួលបានពីការប្រមូលឯកសារនានាដោយផ្សារភ្ជាប់ទៅនឹងទ្រឹស្តី ដើម្បីសិក្សាស្រាវជ្រាវអំពីប្រធានបទ ដែលមានដូចខាងក្រោម៖

-ឯកសារទទួលបានពី លោកប្រធានសាខានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាខាទឹកថ្លា ស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

-ឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត ដែលផ្តល់ដោយនាយកដ្ឋានឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

-ឯកសារមេរៀនដែលបានសិក្សាកន្លងមក និងទទួលបានពីសាស្ត្រាចារ្យ

-ទិន្នន័យស្រាវជ្រាវតាមរយៈរបាយការណ៍កម្មសិក្សារបស់និស្សិតជំនាន់មុនៗ

-ឯកសារស្រាវជ្រាវតាមរយៈបណ្តាញអ៊ិនធើណេត

-របាយការណ៍ធនាគារជាតិ

-គេហទំព័ររបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

## ៥. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា មានផលិតផល និង សេវាកម្មហិរញ្ញវត្ថុជាច្រើន។ ដោយឡែកការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះ គឺផ្តោតសំខាន់ទៅលើតែការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ដែលប្រព្រឹត្តិទៅនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លាតាមរយៈការចុះកម្មសិក្សារយៈពេលមួយខែ គឺចាប់ពីថ្ងៃទី ២០ ខែមេសា ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ចំពោះការសិក្សាស្រាវជ្រាវនេះមិនបានធ្វើការប្រៀបធៀប គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ជាមួយស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀតទេ គឺក្រុមយើងខ្ញុំសិក្សាស្រាវជ្រាវ និងធ្វើការវិភាគទិន្នន័យក្នុងឆ្នាំ ២០១៤-២០១៦ ដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា សម្រាប់ការសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំ ២០១៩ តែប៉ុណ្ណោះ។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់ចំពោះធនាគារ៖ ជាជំនួយដល់ប្រព័ន្ធធនាគារបានយល់ដឹងបន្ថែមនូវព័ត៌មានស្តីពីប្រសិទ្ធភាពនៃការផ្តល់ឥណទានខ្នាតតូច និងមធ្យមចំពោះអតិថិជនរបស់ខ្លួន និងបានយល់ច្បាស់ពីតម្រូវការរបស់អតិថិជនក្នុងការកាត់បន្ថយនូវចំណុចខ្សោយ ឬ ចំណុចខ្វះខាតផ្សេងៗដើម្បីឲ្យមានភាពប្រសើរជាងមុនថែមទៀត។

- សារៈសំខាន់ចំពោះនិស្សិត៖

-បង្កើនចំណេះដឹងចំពោះការអនុវត្តលើវិស័យធនាគារ និងស្ថាប័នហិរញ្ញវត្ថុ

-ទុកជាបទពិសោធន៍សម្រាប់ការបំពេញការងារនាពេលអនាគត

-ទុកជាឯកសារសម្រាប់ដល់និស្សិតជំនាន់ក្រោយៗទៀត

-បំពេញក្នុងតម្រូវការសម្រាប់ បញ្ចប់សារណារបស់យើងខ្ញុំ។

- ចំពោះសាធារណៈជន

-ជាជំនួយដល់អតិថិជនបានយល់ពី ប្រសិទ្ធភាពនៃដំណើរការឥណទាន ការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន

-យល់ច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឥណទាន និងផលិតផលរបស់គ្រឹះស្ថាន

- ចំពោះគ្រឹះស្ថាន

-មិនតែប៉ុណ្ណោះផ្តល់ជាព័ត៌មានសម្រាប់ អ្នកគ្រប់គ្រងយកទៅពិចារណាក្នុងគោលបំណងកែលម្អចំណុចខ្សោយរបស់ខ្លួនឲ្យមានប្រសិទ្ធភាពឡើយវិញ

-អាចធ្វើការបង្ហាញពីប្រសិទ្ធភាពក្នុងដំណើរការប្រតិបត្តិការឥណទានរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង និងធ្វើឲ្យគ្រឹះស្ថានមានកេរ្តិ៍ឈ្មោះកាន់តែល្បីល្បាញ។

## ៧. គម្រោងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើការបែងចែកជាបីជំពូកដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១ រំលឹកទ្រឹស្តី
- ជំពូកទី២ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា
- ជំពូកទី៣ ឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

**សេចក្តីផ្តើម**

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

- លក្ខណៈទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- លក្ខណៈទូទៅរបស់ឥណទាន
- នីតិវិធីគ្រប់គ្រងការផ្តល់ឥណទាន
- ការគ្រប់គ្រងហានិភ័យឥណទាន
- ការដោះស្រាយបំណុលមានបញ្ហា

**ជំពូកទី២**

**ជំពូកទី៣**

**សិក្សាពីស្ថានភាពជាក់ស្តែងក្នុងស្ថាប័ន**

- ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ
- គោលការណ៍ឥណទានខ្នាតតូច និងមធ្យម
- នីតិវិធីគ្រប់គ្រងការផ្តល់ឥណទាន
- ការគណនាការប្រាក់ និងការសងត្រឡប់
- ការដោះស្រាយបំណុលមានបញ្ហា
- ការវិភាគគុណភាពឥណទាន

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. លក្ខណៈទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ១.១.១. ប្រវត្តិនៃការកកើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

[1]ចាប់តាំងពីឆ្នាំ ១៩៧៩ ក្រោយពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមដ៏វិនាសកម្មក្រោមការគ្រប់គ្រងផ្តាច់ការក្នុងរបប ប៉ុល ពត ដែលមានរយៈពេលរហូតដល់ទៅបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនោះមក ធ្វើឲ្យប្រទេសជាតិ ធ្លាក់ដល់ចំនុចសូន្យដោយគ្មាន បន្សល់ទុកនូវអ្វីទាំងអស់រាប់ចាប់តាំងពីហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង វិស័យសេដ្ឋកិច្ច វិស័យទូរគមនាគមន៍ វិស័យធនាគារ និងវិស័យផ្សេងៗទៀត។ជាពិសេសទៀតនោះគឺធនធានមនុស្សនេះតែម្តងគឺបានរលាយអស់ស្ទើរទាំងស្រុង។ ទើបតែក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩មក ទើបប្រទេសជាតិបានចាប់ផ្តើមងើបឡើងបន្តិចម្តងៗ និងវិស័យផ្សេងៗក៏មានដំណើរការជាហូរហែឡើងវិញផងដែលរាប់ទាំងវិស័យធនាគារ និងហិរញ្ញវត្ថុផងដែរ។ ហើយបើនិយាយពីវិស័យមីក្រូហិរញ្ញវត្ថុវិញ គឺបានចាប់ផ្តើមមកកើតជាថ្មីឡើងវិញ អំឡុងទសវត្សឆ្នាំ១៩៩០ ដែលប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅពេលនោះ គឺស្ថិតនៅក្រោមសកម្មភាពជាលក្ខណៈអង្គការក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះ។ ការកកើតឡើងវិញរបស់មីក្រូហិរញ្ញវត្ថុនៅទសវត្សនោះ គឺដើម្បីបំពេញបន្ថែមនូវការខ្វះចន្លោះរបស់ធនាគារ ជាពិសេសធនាគារពាណិជ្ជដែលមិនបានបម្រើសេវាឥណទានទៅដល់ទីជនបទដាច់ស្រយាល ដែលនៅទសវត្សនោះ គឺធនធានបានស្រូបយកអតិថិជនបានត្រឹមតែ២០% នៃប្រជាពលរដ្ឋសរុបក្នុងទូទាំងប្រទេសតែប៉ុណ្ណោះ ហើយប្រជាពលរដ្ឋទាំងនោះ គឺភាគច្រើនគឺជាអ្នកដែលមានសេដ្ឋកិច្ចគ្រួសារប្រសើរ និងធូរធារមធ្យមផងដែរ ហើយអ្នកទាំងនោះគឺភាគច្រើនរស់នៅទីប្រជុំជន និងទីក្រុង។ ដូច្នេះក្រៅពីនោះ គឺប្រជាពលរដ្ឋមិនមានឱកាសក្នុងការទទួលបានប្រាក់កម្ចីឥណទានពីធនាគារ ដែលយកការប្រាក់ទាបសមរម្យនោះទេ។ កត្តាមួយទៀតនោះ គឺដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឲ្យបានខ្ចីប្រាក់ ដែលមានអត្រាការប្រាក់ទាបសមរម្យជាងឈ្មួញចងការប្រាក់នៅតាមភូមិស្រុករបស់ពួកគាត់តាមរយៈការខ្ចីប្រាក់ឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅពេលដែលប្រជាពលរដ្ឋចង់ខ្ចីប្រាក់ ដើម្បីយករយៈការខ្ចីប្រាក់ឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅពេលដែលប្រជាពលរដ្ឋចង់ខ្ចីប្រាក់ ដើម្បីយកទៅប្រកបមុខរបរផ្សេងៗ ឬពង្រីកមុខរបរ ឬធ្វើអ្វីមួយនៅមុនទសវត្ស១៩៧៩ ដល់ ១៩៩០ ពួកគាត់ មានតែម្យ៉ាងគត់គឺទៅរកខ្ចីប្រាក់ឈ្មួញចងការប្រាក់ដែលរស់នៅតាមភូមិ ស្រុក របស់គាត់ដែលនៅពេលនោះទោះបី

[1] http://www.amret.com.kh/amret/index.php/km/2012-08-06-03-28-30/2012-10-01-06-35-24

អត្រាការប្រាក់ ដែលឈ្មួញចងការប្រាក់ទាំងនោះបានយកការប្រាក់ខ្ពស់ គឺខ្ពស់រហូតអាចនិយាយផងដែរថាការប្រាក់១០% ឬ ២០%ក្នុងមួយខែៗគឺមិនថ្លៃទេសំរាប់គាត់។ដោយសារតែពួកគាត់គ្មានអ្នកឲ្យខ្ចីប្រាក់ណាផ្សេងៗទៀត ដើម្បីយកមកធ្វើការប្រៀបធៀបឡើយក្រៅតែពីឈ្មួញចងការប្រាក់នៅភូមិ ស្រុករបស់ពួកគាត់។ កត្តាទាំងនេះហើយធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានចាប់ផ្តើមដើរតួនាទីឡើងវិញក្នុងនាមជាប្រតិបត្តិករក្នុងការចូលទៅបំពេញនូវចន្លោះខ្វះខាតទាំងនេះដើម្បីឲ្យប្រជាពលរដ្ឋ ដែលភាគច្រើនជាស្ត្រីឲ្យមានឱកាសក្នុងការខ្ចីប្រាក់ យកទៅចាប់ផ្តើមមុខរបរ ឬ ពង្រីកមុខរបរដែលមានស្រាប់ឲ្យកាន់តែប្រសើរឡើងតាមរយៈការខ្ចីប្រាក់ឥណទាន ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ សកម្មភាពទាំងនេះ គឺសបញ្ជាក់ឲ្យឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិតជាបានដើរតួនាទី យ៉ាងសំខាន់ និងយ៉ាងសកម្ម និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការជួយស្តារ និងធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ដែលឲ្យកាន់តែប្រសើរឡើងថែមទៀត ស្របទៅនិងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងបើកទូលាយ នូវគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរីទាំងក្នុងប្រទេស និងក្រៅតំបន់ និងទាំងនៅលើឆាកអន្តរជាតិផងដែរ។ ជាមួយនេះផងដែលរាជរដ្ឋាភិបាលដែលមាន សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ និងប្រកាសឆ្នាំ២០០៦ គឺជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា[2] ។ [3]ការចេញអាជ្ញាប័ណ្ណរបស់ធនាគារជាតិនៃកម្ពុជា ដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងបណ្តាឆ្នាំអំឡុងទស្សវត្ស ១៩៩៨-២០០០ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកដុះដាល និងបានក្លាយជាវិស័យមួយដែលមានសក្តានុពលហើយមានការរីកចម្រើនយ៉ាងខ្លាំងក្លាបើធ្វើការប្រៀបធៀបទៅ នឹងបណ្តាប្រទេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ទន្ទឹមនឹងការវិវត្តន៍យ៉ាងខ្លាំងនេះហើយទើបធនាគារនៃកម្ពុជា ដែលជាអាណាព្យាបាលលើគ្រឹះស្ថានធនាគារ និងក៏ដូចជាមីក្រូហិរញ្ញវត្ថុបានចេញច្បាប់មួយស្តីពីគ្រឹះស្ថានធនាគារ និង មីក្រូហិរញ្ញវត្ថុក្នុងការផ្តល់អាជ្ញាប័ណ្ណជូនគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុដែលជាប្រតិបត្តិករ។ ការចេញអាជ្ញាប័ណ្ណនេះ គឺក្នុងគោលបំណង ដើម្បីធានានិរន្តរ៍ភាពរបស់គ្រឹះស្ថានទាំងនោះឲ្យដំណើរការទៅដោយរលូន និងស្របច្បាប់ ដែលបានកំណត់ដោយនិរន្តរ៍ភាពរបស់គ្រឹះស្ថានទាំងនោះឲ្យដំណើរការទៅដោយរលូន និងស្របច្បាប់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ដែលជាអាណាព្យាបាល។ ច្បាប់នេះរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ នា

[2]Sector highlight: Cambodia Microfinance: Development and Challenges by Mr. Kim Vada, Deputy Director General for National Bank of Cambodia, on March 15-17, 2010 at Dhaka, Bangladesh)

[3]www.nbc.org.kh/legislation/law_on_banking_and_financial_institutions.php, ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

សម័យប្រជុំពេញអង្គលើក ទី៣ នីតិកាលទី២។ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមធម្មនុញ្ញ កាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលមានសេចក្តីទាំងស្រុង ស្តីពីច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយក្នុងច្បាប់នោះត្រង់ជំពូក៤ មាត្រា១៤ គឺបានបញ្ជាក់យ៉ាងច្បាស់ ស្តីពីការចេញអាជ្ញាប័ណ្ណជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (សេចក្តីលំអិតមានក្នុងច្បាប់របស់ធនាគារជាតិនៃកម្ពុជា)។

នៅត្រឹម ២០១៥ គឺមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៥៨ ដែលទទួលអាជ្ញាប័ណ្ណស្របច្បាប់ពីធនាគារជាតិនៃកម្ពុជាក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។ ហើយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង៥៨ នោះគឺមានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨ ទេ ដែលទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណៈជន។[4]

### ១.១.២. និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

មុននឹងឲ្យនិយមន័យ " អ្វីទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ " យើងត្រូវតែយល់ន័យនៃពាក្យមីក្រូហិរញ្ញវត្ថុជាមុនសិន។

និយមន័យពាក្យថា មីក្រូហិរញ្ញវត្ថុ អាចមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយតាមបទដ្ឋានគតិយុត្តិនៃប្រទេសនោះ។

មីក្រូហិរញ្ញវត្ថុ (មីក្រូ=តូចបំផុត , ហិរញ្ញវត្ថុ=ការគ្រប់គ្រងហិរញ្ញវត្ថុ) សកម្មភាពផ្តល់សេវាឥណទាន ឬទទួលប្រាក់សន្សំដែលមានទំហំតូចតាច[5] ។មីក្រូហិរញ្ញវត្ថុ មានន័យថាការផ្តល់សេវាហិរញ្ញវត្ថុដូចជា ការផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើចំពោះគ្រួសារដែលមានចំណូលតិច និងសហគ្រាសខ្នាតតូច[6] ។ មួយផ្សេងទៀតមីក្រូហិរញ្ញវត្ថុមានន័យថា ជាការផ្តល់នូវបណ្តាសេវាមីក្រូហិរញ្ញវត្ថុទាំងឡាយដូចជាសេវាប្រាក់បញ្ញើ កម្ចី សេវាទូទាត់ ផ្ទេរប្រាក់ ដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមគ្រួសារដែលមានចំណូលទាប (Low-Income Households) ហើយព្រមទាំងមីក្រូសហគ្រាស (Microenterprises)ផងដែរ។គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានដែលផ្តល់នូវបណ្តាសេវាហិរញ្ញវត្ថុទាំងឡាយដូចជា សេវាប្រាក់បញ្ញើ កម្ចី សេវាទូទាត់ ផ្ទេរប្រាក់ ដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមគ្រួសារដែលមានចំណូលទាប ហើយព្រមទាំងមីក្រូសហគ្រាសផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថាប័ណ្ណមួយដែលបានចុះបញ្ជីជាក្រុមហ៊ុន ហើយអាចធ្វើពាណិជ្ជកម្មបានលុះត្រាតែទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ជាមួយនឹងដើមទុនអតិបរមាក្នុងលក្ខន្តិកកំណត់មួយ។

[4]http://www.nbc.org.kh/economic_research/mfis_reports.php

[5]ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, <<វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច>>, ទំព័រ ៤៨៤

[6]ធនាគារជាតិនៃកម្ពុជា, ២០០៨, <<ច្បាប់ក្រមអនុវត្តចំពោះធនាគារ និង ហិរញ្ញវត្ថុ>>, ទំព័រ ៥៥១

ម្យ៉ាងទៀត វាជាស្ថាប័នហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ មានន័យថាចំនួនទឹកប្រាក់ដែលឲ្យខ្ចីមានទំហំតូច ហើយវាក៏ជាយន្តការមិនអាចខ្វះបាន ក្នុងការជួយជំរុញកំណើន សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ ដោយធ្វើឲ្យប្រភពធនធានដែលនៅក្នុងបុគ្គលនីមួយៗ មានវត្តមាននៅលើទីផ្សារ។ ដូច្នេះហើយបើគ្មានស្ថាប័នហិរញ្ញវត្ថុទេ ដំណើរការនៃប្រព័ន្ធហិរញ្ញវត្ថុពិតជាជួបនូវបញ្ហាជាមិនខាន។

### ១.១.៣.គោលបំណងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គោលបំណងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺរៀបចំនូវសេចក្តីត្រូវការខាងហិរញ្ញវត្ថុ ដល់ពលរដ្ឋក្រីក្រ និងកាត់បន្ថយនូវអត្រាការប្រាក់ខ្ពស់នៅលើទីផ្សារ ដោយយកឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុទៅជំនួសនូវការខ្ចីបំណុលផ្សេងៗ។

ដោយពិនិត្យឃើញថា ឥណទានជាយន្តការយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍជនបទ ដែលមានតួនាទីជួយបង្កើន និងពង្រីកនូវមុខរបរ ព្រមទាំងបង្កើតនូវផលិតភាពការងារ និងប្រាក់ចំណូលដែលធ្វើឲ្យជីវភាពរបស់ប្រជាជនបានល្អប្រសើរឡើង ហើយក៏ជាផ្នែកមួយរួមចំណែកយ៉ាងសំខាន់ និងសកម្មបំផុតក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជនបទថែមទៀត។

### ១.១.៤. តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងការអភិវឌ្ឍជនបទតាមរយៈការផ្តល់សេវាឥណទាន ដែលធ្វើឲ្យមានលំហូរសាច់ប្រាក់ ក្នុងចរន្តសេដ្ឋកិច្ចបង្កើតឲ្យមានសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតយ៉ាងសម្បូរបែប។ ខាងក្រោមនេះ គឺបង្ហាញពីសារៈសំខាន់ និងតួនាទីឥណទានៈ

-ផ្តល់ទុនដល់កសិករសម្រាប់ទិញឧបករណ៍ និងមធ្យោបាយកសិកម្ម

-បង្កើតឲ្យមាននីយកម្មភាព (Employment)ដើម្បីកសាងសេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ

-ផ្តល់ឥណទានឲ្យកសិករដើម្បីរក្សានូវផលិតផលកសិកម្មរបស់ខ្លួន និងអាចលក់នៅពេលណាដែលមានតម្លៃសមរម្យ

-ផ្តល់នូវធនធានហិរញ្ញវត្ថុសម្រាប់បង្កើត ពង្រីក និងកែលំអមុខរបរឲ្យបានប្រសើរ

-ផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈ លើវិស័យកសិកម្ម ដើម្បីឲ្យកសិករចេះរៀបចំគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចបានត្រឹមត្រូវស្របនឹងកម្មវិធីនៃការប្រើប្រាស់ឥណទាន។

-ផ្តល់ព័ត៌មាន និងវិធីសាស្ត្រផ្សេងៗដូចជា វិធីសាស្ត្រគ្រប់គ្រងមុខរបរ វិធីសាស្ត្រផលិតទំនិញ និងការជួញដូរលើទីផ្សារ។

-កាត់បន្ថយការប្រើប្រាស់ឥណទាន ដែលមានការប្រាក់ខ្ពស់ហួសហេតុពីបណ្តាឈ្មួញនានា។

-បង្កើនការងារជូនប្រជាពលរដ្ឋតាមគ្រប់មធ្យោបាយ ដែលមានស្រាប់នៅនឹងកន្លែង ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកភូមិ ដើម្បីស្វែងរកការងារធ្វើនៅតាមទីក្រុង ទីប្រជុំជន និងតាមបណ្ដាប្រទេសផ្សេងៗទៀត។

-បង្កើនផលិតផលក្នុងស្រុកសរុប និងសេវាកម្មដើម្បីបន្ថយការកែច្នៃ និងបែងចែកផលិតផល

កសិកម្មឲ្យមានភាពរីកចម្រើនជាងមុន។

-ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដោយជម្រុញឲ្យមានការវិនិយោគកម្រិតតូច និងមធ្យមដើម្បីបង្កើតឲ្យមានផលិតផល និងសេវាកម្មផ្សេងៗគ្នា ក្នុងគោលបំណងដើម្បីបម្រើឲ្យវិស័យសេដ្ឋកិច្ចក្នុងគ្រួសារ និងសង្គមជាតិទាំងមូល។

-ពង្រឹងសាមគ្គីភាព និងការអនុវត្តច្បាប់បានល្អក្នុងចំណោមសមាជិកសហាគមន៍។

## ១.២. លក្ខណៈទូទៅរបស់ឥណទាន

### ១.២.១. និយមន័យឥណទាន

ឥណទាន ត្រូវបានគេឲ្យនិយមន័យខុសៗគ្នា ដោយយោងទៅតាមវិស័យនីមួយៗ តាមរយៈគោលបំណង និងកម្មវត្ថុសំខាន់ៗរបស់ឥណទានទាំងនោះ៖

ឥណទាន គឺជាទុនដែលត្រូវបានផ្ដល់ឲ្យ ដោយអ្នកផ្ដល់ឥណទានចំពោះអ្នកខ្ចី ដែលសន្យាសងត្រឡប់មកវិញនាពេលអនាគតរួមជាមួយការប្រាក់[7] ។

ឥណទាន គឺជាការឲ្យខ្ចីជាប្រាក់ ឬអ្វីៗដែលសម្រាប់ឲ្យខ្ចី[8]។

ឥណទាន គឺជាការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ជាបណ្ដោះអាសន្នទៅឲ្យអ្នកខ្ចី នូវបរិមាណតម្លៃមួយអាចជាវត្ថុ ឬជារូបិយវត្ថុ ជាមួយនឹងការសន្យាសងត្រឡប់ទៅឲ្យម្ចាស់ដើមវិញនូវបរិមាណធំជាងមុន។ លក្ខណៈពិសេសនៃឥណទានមានបីយ៉ាង៖

- ការផ្ទេរសិទ្ធិប្រើប្រាស់ ពីម្ចាស់កម្មសិទ្ធិស្របច្បាប់ទៅឲ្យជនម្នាក់ទៀត
- ការផ្ទេរសិទ្ធិប្រើប្រាស់នេះ ជាការផ្ទេរសិទ្ធិបណ្ដោះអាសន្នតែប៉ុណ្ណោះ
- នៅពេលដល់ការកំណត់អ្នកខ្ចីត្រូវធ្វើការទូទាត់នូវចំនួនដែលបានខ្ចីជាមួយនឹងថ្លៃឈ្នួលឲ្យខ្ចី[9]។

សរុបសេចក្ដីមកតាមន័យហិរញ្ញវត្ថុ ឥណទាន មានន័យថា គឺជាការផ្ដល់ប្រាក់កម្ចីដោយគិត

[7] Mr. Long Mamidi.2012-2013, Personal Finance,ទំព័រទី២៥

[8] ជួន ណាត, ១៩៦៧,"វចនានុក្រមខ្មែរ" ទំព័រ ១៧៦៥

[9] ភឹម សុបំណង, ២០១១,គ្រប់គ្រងឥណទាន,ទំព័រ ៣

ការប្រាក់ទៅលើប្រាក់ដើម ដែលផ្តល់ឲ្យអតិថិជន ទៅតាមតម្រូវការសាច់ប្រាក់ដែលបានខ្ចី ដើម្បីយកទុនទៅដោះស្រាយបញ្ហារបស់ខ្លួន និងដំណើរការអាជីវកម្ម។ ចំពោះការខ្ចីប្រាក់ត្រូវសងត្រឡប់មកវិញនូវប្រាក់ដើម និងការប្រាក់តាមការកំណត់ក្នុងកិច្ចសន្យារបស់ឥណទាន។

### ១.២.២. ប្រភេទនៃឥណទាន

ឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានគេបែងចែកជាពីរប្រភេទគឺៈ ឥណទានទោល(Individual Loan) និង ឥណទានក្រុមធានា (Group Loan)។

#### ១.២.២.១. ឥណទានទោល

[10]ឥណទានទោល (Individual Loan) គឺជាការផ្តល់ឥណទានជូនអតិថិជនជាឯកត្តជនដោយតម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមានការខកខានមិនបានសងបំណុល។ឥណទានប្រភេទនេះ គឺផ្តល់សម្រាប់មុខជំនួញខ្នាតតូច និងមធ្យម។

#### ១.២.២.២. ឥណទានក្រុម (Group Loan)

ឥណទានក្រុម គឺជាឥណទានសម្រាប់ផ្តល់ជូនប្រជាកសិករក្រីក្រ ដែលមានមុខជំនួញ ឬកសិកម្មតូចតាចដោយមិនតម្រូវឲ្យដាក់ទ្រព្យសម្បត្តិធានាទេ (តែគ្រឹះស្ថានខ្លះតម្រូវឲ្យមានទ្រព្យធានា)ប៉ុន្តែអតិថិជនត្រូវបានចងគ្នាជាក្រុមពី បីទៅដប់នាក់។ ការចងគ្នាជាក្រុមបែបនេះ គឺសម្រាប់ឲ្យសមាជិកក្នុងក្រុម ធានាគ្នាទៅវិញទៅមក និងត្រូវចេញសងជូសគ្នាប្រសិនបើសមាជិកណាម្នាក់ខកខានមិនបានសង។

### ១.២.៣. អត្ថប្រយោជន៍ឥណទាន

ឥណទាន មានសារៈសំខាន់ណាស់ សម្រាប់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក៏ដូចជាអាចជួយស្តារសេដ្ឋកិច្ចរបស់សង្គមជាតិមួយផ្នែកដែរ។ ឥណទានមានមុនពីរ កាលណាឥណទាន ត្រូវបានផ្តល់ដោយយុទ្ធសាស្ត្រត្រឹមត្រូវ នោះនឹងទទួលបានអត្ថប្រយោជន៍ ប៉ុន្តែបើមិនត្រឹមត្រូវទេនោះអាចប្រឈមមុខនឹងបញ្ហាគ្រប់ពេលវេលា។ ចំពោះអត្ថប្រយោជន៍មានដូចខាងក្រោមៈ

#### ១.២.៣.១. សម្រាប់អតិថិជន

អតិថិជនអាចទទួលបានដើមទុនពង្រីកអាជីវកម្មរបស់ខ្លួន ឬធ្វើការពង្រីកអាជីវកម្មដើម្បីមានសមត្ថភាពប្រកួតប្រជែងលើទីផ្សារ ហើយអាចទទួលបានប្រាក់ចំណេញបន្ថែម។ ម្យ៉ាងវិញទៀតតាមរយៈឥណទាន អតិថិជនអាចមានលទ្ធភាពរៀបចំស្តង់ដារជីវភាពរស់នៅឲ្យកាន់តែប្រសើរអាចទិញសម្ភារៈប្រើប្រាស់ សង់គេហដ្ឋាន កែលំអគេហដ្ឋាន នឹងអាចឲ្យពួកគាត់ចេះប្រើ

[10]ម៉ៃ សុខជេដ្ឋា, ២០០៥, "ស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា", ទំព័រ ៤២

ជីវិតតាមបែបសម័យថ្មី...។

**១.២.៣.២. សម្រាប់អាជីវកម្ម**

-ពង្រីកទីផ្សារ : ការធ្វើអាជីវកម្មពឹងផ្អែកលើឥណទាន ដើម្បីពង្រីកទីផ្សារ និងស្វែងរកអតិថិជន។ ឧទាហរណ៍ ដូចជាការលក់ដោយជំពាក់ គឺដើម្បីប្រកួតប្រជែង និងតម្រូវការនៃឥណទានសម្រាប់ការរស់រាននៃអាជីវកម្ម។

- មូលនិធិហិរញ្ញវត្ថុចាំបាច់ : អាជីវកម្មជាច្រើនត្រូវការដើមទុន ដើម្បីចាប់ផ្តើមអាជីវកម្មឲ្យមានដំណើរការ និងពង្រីកប្រតិបត្តិការដូចជាទីតាំង សាខាថ្មី និយោជិកថ្មី និងការចំចំណាយលើទីផ្សារដូចជាដើមទុនមានភាពចាំបាច់ណាស់សម្រាប់អាជីវកម្ម បើគ្មានទុនទេ នោះអាជីវកម្មមិនអាចមានដំណើរការបានទេ។

**១.២.៣.៣. សម្រាប់ធនាគារ**

គ្រឹះស្ថានអាចទទួលបានការប្រាក់ពីឥណទាន ហើយបន្តសេវាកម្មរបស់ខ្លួនសម្រាប់អ្នកមានតម្រូវការដើមទុន និងពង្រីកអាជីវកម្មរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង។

**១.២.៣.៤. សម្រាប់សេដ្ឋកិច្ច**

យោងលើឥណទាន ជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតជាចលនាសាច់ប្រាក់ និងជាផ្នែកនៃផលិតកម្មនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ ឥណទានតែងផ្តល់មធ្យោបាយ ដើម្បីសេរីភាពដល់កម្រិតសកម្មភាពសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុខុសៗគ្នា។ តួនាទីរបស់ឥណទានមានសារៈសំខាន់ជាពិសេសនៅក្នុងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ ដែលមានឥទ្ធិពលលើការចំណាយ និងការត្រួតពិនិត្យអត្រាការប្រាក់[11] ។

**១.២.៣.៥. សម្រាប់សង្គម**

កាលណាមានសេវាឥណទាន ពេលនោះភាពខ្វល់ខ្វាយលើបញ្ហាខ្វះដើមទុន ត្រូវបានដោះស្រាយដែលបណ្តាពាណិជ្ជករអាចចាប់ផ្តើមអាជីវកម្ម ឬពង្រីកអាជីវកម្មដើម្បីឲ្យផលិតកម្មមានការកើនឡើង។ ស្របពេលជាមួយគ្នា តម្រូវការកម្លាំងពលកម្មក៏មានការកើនឡើង និងធ្វើឲ្យនិយកម្មភាពមានការធ្លាក់ចុះ ចំណូលប្រជាពលរដ្ឋកើនឡើង ឯរដ្ឋាភិបាលអាចមានលទ្ធភាពទទួលបានឥណទាន ដើម្បីបង្កើនចំណាយសាធារណៈដូចជា សាងសង់សាលារៀន ស្ពានថ្នល់ មន្ទីរពេទ្យប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលធ្វើឲ្យការវិនិយោគកើនឡើង ប្រទេស

[11]Robert Cole and Lon Mishler,1998 ,Consumer and Business Credit Management International Edition Pag11-12

ទាំងមូលមានការអភិវឌ្ឍន៍នាំឲ្យទទួលបានសង្គមមួយដែលមានសុខុមាលភាព និង សន្តិភាព។

### ១.២.៤. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទាន

នៅក្នុងភាពជាក់ស្តែង ឥណទានអាចមានផលអាក្រក់ នៅពេលដែលយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ ហើយវាក៏អាចបង្កជាបញ្ហាជាច្រើនសម្រាប់អាជីវកម្ម អ្នកប្រើប្រាស់ និងសហគមន៍ទាំងមូល។ អ្នកប្រើប្រាស់ឥណទានទាំងអស់ត្រូវដឹងថា ឥណទានដែលកំពុងប្រើ គឺប្រើសម្រាប់តែគោលបំណងផលិតភាពតែប៉ុណ្ណោះ និងចេះបង្កើនការប្រុងប្រយ័ត្នជាមួយស្មារតីយកចិត្តទុកដាក់ខ្ពស់។

#### ១.២.៤.១. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់

អ្នកប្រើប្រាស់អាចប្រើឥណទានមិនបានត្រឹមត្រូវ នឹងទទួលមកវិញនូវបទពិសោធន៍មិនល្អ។ ដោយការប្រើប្រាស់ឥណទានមិនបានល្អ អាចធ្វើឲ្យមានបញ្ហាដល់អ្នកប្រើប្រាស់ជាយថាហេតុ ក្នុងការបាត់បង់នូវលទ្ធភាពទូទាត់បំណុល ។ ឥណទានជាអន្ទាក់មួយសម្រាប់អ្នកប្រើប្រាស់ ដែលប្រើខុសទិសដៅហើយលទ្ធផលចុងក្រោយអាចឈានដល់ការបាត់បង់ទ្រព្យសម្បត្តិ ការក្ស័យធន បែកបាក់ចំណងអាពាហ៍ពិពាហ៍ និងមានកម្រិតគុណភាពឥណទានទាប។ ម្យ៉ាងវិញទៀតកាលណាដែលជាប់សន្យាជាច្រើននៃចំណូលអនាគតជាមួយឥណទានធ្វើឲ្យបាត់បង់ឱកាសសន្សំដែលជាគោលដៅយ៉ាងសំខាន់។

#### ១.២.៤.២. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម

ជំនួញត្រូវមានការប្រុងប្រយ័ត្ននៅពេលដែលមានឥណទាន។ ពេលដែលមានអតិថិជនមួយចំនួនបានទិញទំនិញ និងសេវាកម្មដោយជម្រើសឥណទាន ហើយមិនបានសងតាមកិច្ចព្រមព្រៀងនោះធ្វើឲ្យអាជីវកម្មនឹងបាត់បង់ចំណូលជាច្រើន។ បញ្ហានេះភាគច្រើនកើតមានចំពោះអាជីវកម្មខ្នាតតូច។ ដូច្នេះ ចំពោះអាជីវកម្មត្រូវប្រាកដថា អតិថិជនល្អទើបមានឱកាសប្រើប្រាស់កម្មវិធីឥណទាន។

## ១.៣. ការគ្រប់គ្រងឥណទាន

### ១.៣.១. គោលដៅរបស់អ្នកគ្រប់គ្រងឥណទាន

[12]អ្នកគ្រប់គ្រងឥណទានត្រូវមានសក្កានុពល (មានសុវត្ថិភាព និង មានភាពឯករាជ្យ) ដើម្បីធានាចំពោះអាជីវកម្មដែលបានធ្វើការវាយតម្លៃទៅលើឆន្ទៈ និង លទ្ធភាពសងរបស់អតិថិជន។ មុននឹងឆ្លងកាត់ដល់ការស៊ើបអង្កេត និងការសម្រេចចិត្ត អ្នកគ្រប់គ្រងឥណទានត្រូវតែប្រមូលផ្តុំនូវព័ត៌មាន ពីគោលដៅខុសគ្នាមួយចំនួនទៀតដូចជា៖

[12]ឯម វាសនា ឆ្នាំ២០១១,ការគ្រប់គ្រងឥណទាន,ទំព័រពី ១០-១៤

### ១.៣.១.១. បង្កើនប្រាក់ចំណូលពីការលក់

អ្នកគ្រប់គ្រងឥណទានស្ថិតក្នុងជំហរមួយយ៉ាងសំខាន់ នៃយុទ្ធសាស្ត្របង្កើនការលក់របស់អង្គភាព។ អង្គភាពមួយនឹងមិនអាចដំណើរការបានយូរអង្វែងទេ បើគ្មានចំណូលអតិថិជនស្ថិតស្ថេរដែលមានបំណងប្រើប្រាស់ឥណទានរបស់អង្គភាព។ អ្នកគ្រប់គ្រងឥណទាននឹងព្យាយាមដើម្បីយល់ព្រមលើសំណើរសុំឥណទានឲ្យបានច្រើនតាមដែលអាចធ្វើបាន។

### ១.៣.១.២. ការត្រួតពិនិត្យលើបរិមាណជំពាក់

ស្ទើរតែគ្រប់ស្ថាប័នហិរញ្ញវត្ថុ ការរៀបចំក្នុងការផ្តល់កម្ចី ឬការផ្តល់ឥណទានដទៃផ្សេងៗទៀតគឺ ជាផលិតផលដែលគេផ្តល់ឲ្យ។ អ្នកគ្រប់គ្រងឥណទាននឹងធ្វើការងារ ដើម្បីពង្រីកទំហំនៃបំណុលដែលផ្តល់កម្ចីកាន់តែច្រើន ការចេញប័ណ្ណឥណទានកាន់តែច្រើន ឬបង្កើតគណនីកាន់តែច្រើនជាមួយនឹង អតិថិជនដែលមានលក្ខណៈសម្បត្តិល្អ។

ការចំណាយលើបំណុលអាក្រក់ (Bad-Debt Expense) ស្ថិតនៅក្នុងផ្នែកមួយនៅក្នុងការកត់ត្រាហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទៅលើបំណុលដែលមិនអាចប្រមូលបាន។ ស្ថានភាពនេះកើតឡើងនៅពេលដែលក្តីសង្ឃឹមទៅលើការប្រមូលបំណុលដែលបានជំពាក់ត្រូវបានបាត់បង់។ ការចំណាយលើបំណុលអាក្រក់ វាពិបាកក្នុងការញែក ពីព្រោះការបាត់បង់ជាទូទៅរួមបញ្ចូលទាំងថ្លៃដើម រួមបញ្ចូលទាំងរាល់បន្ទុកហិរញ្ញវត្ថុដែលមាន។ អ្នកគ្រប់គ្រងឥណទានត្រូវតែពិនិត្យជាប់ជានិច្ចពីប្រសិទ្ធភាពនៃសកម្មភាពការប្រមូលបំណុល ដើម្បីបង្ហាញពីនិន្នាការ និងធ្វើឲ្យលទ្ធផលកាន់តែប្រសើរឡើង។

### ១.៣.១.៣. ពិនិត្យសោហ៊ុយប្រតិបត្តិការ និងចំណាយ

ដំណើរការឥណទានទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងទាំងធនធានមនុស្ស និងការចំណាយមូលធនសម្រាប់ឧបករណ៍ប្រើប្រាស់ និងការទូទាត់ទៅលើសេវាកម្មខាងក្រៅដែលរួមចំណែកដល់ប្រតិបត្តិការឥណទាន។ ការចំណាយលើប្រាក់ខែ សម្ភារៈការិយាល័យ កុំព្យូទ័រ ការស៊ើបអង្កេត និងការប្រមូលត្រូវបានទូទាត់។ អ្នកគ្រប់គ្រងឥណទានត្រូវតែសម្រេចចិត្ត ប្រសិនបើអត្ថប្រយោជន៍ធំជាងការចំណាយទាំងនេះ។

### ១.៣.១.៤. ការកាត់បន្ថយចំណាយលើការប្រមូល និងបំណុលពិបាកទារ

បន្ទាប់ពីការផ្តល់កម្ចីត្រូវបានធ្វើឡើង អ្នកគ្រប់គ្រងឥណទានត្រូវតែរង់ចាំការទូទាត់ទៅលើបំណុលដែលជំពាក់។ កិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលបំណុលឲ្យមានប្រសិទ្ធភាពទាក់ទងទៅនឹងការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នទៅលើគណនី និងឆ្លើយតបយ៉ាងឆាប់រហ័ស នៅពេលដែលមិន

មានការទូទាត់សងត្រឡប់មកវិញ។

### ១.៣.១.៥. បង្កើតគោលនយោបាយឥណទាន និងការប្រមូល

ស្ទើរតែគ្រប់ផ្នែកឥណទានអាជីវកម្មសម័យថ្មី បានកំណត់ច្បាស់ ពីគោលនយោបាយឥណទាន និង ប្រមូលបំណុល ។ គោលនយោបាយឥណទានគឺ ជាគោលការណ៍ណែនាំជាលាយលក្ខអក្សរដល់បុគ្គលិកឥណទាន។ គោលការណ៍ណែនាំនេះបញ្ជាក់ពីលក្ខណៈសម្បត្តិ និងតម្រូវការជាមូលដ្ឋាន

សម្រាប់ការសម្រេចចិត្តថា តើអតិថិជនមួយណាដែលត្រូវបានផ្តល់ឥណទានជូន?

### ១.៣.១.៦. បណ្តុះបណ្តាល និងត្រួតពិនិត្យនិយោជិក

នៅក្នុងផ្នែកឥណទាន អ្នកគ្រប់គ្រងឥណទានត្រូវបង្កើតយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីចាំបាច់នានា ដើម្បីសម្រេចគោលដៅនៃផ្នែកឥណទានជាមូលដ្ឋាន។ បុគ្គលិកឥណទានគួរតែរៀបចំតាមជំនាញ ដែលត្រូវនឹងសមត្ថភាពរបស់ពួកគេ និងប្រសិនបើចាំបាច់ការហ្វឹកហាត់បន្ថែមគឺតម្រូវឲ្យមាន។ ការវាយតម្លៃការងារ (Performance Appraisal) និងការវាស់វែង ការគ្រប់គ្រងដទៃទៀតត្រូវតែអនុវត្ត ដើម្បីឲ្យធានាប្រាកដថា បុគ្គលិកធ្វើការឲ្យអស់ពីសមត្ថភាពរបស់ពួកគេ។

### ១.៣.១.៧. រក្សាទំនាក់ទំនងល្អជាមួយអតិថិជន

ការឲ្យឥណទាន និងសកម្មភាពនៃការប្រមូលបំណុល បានផ្តល់ឱកាសជាច្រើនក្នុងការទទួលបានចំណូល ឬក៏អាចបំផ្លាញនូវសេចក្តីពេញចិត្តរបស់អតិថិជន។ ជំនាញក្នុងការប្រាស្រ័យទាក់ទងល្អត្រូវបានអនុវត្តដោយមនុស្សគ្រប់គ្នា ដែលត្រូវជួបទាក់ទងជាមួយអតិថិជន។ ពេលខ្លះការសន្ទនា និងសំណើរសុំទូទាត់សងតម្រូវឲ្យមានជំនាញក្នុងការចរចារ។ បុគ្គលិកត្រូវតែមានភាពរួសរាយរាក់ទាក់ ប៉ុន្តែពួកគេត្រូវដោះស្រាយជាមួយអតិថិជននៅក្នុងអាជីវកម្មផងដែរ។

## ១.៣.២. នីតិវិធីនៃការផ្តល់ឥណទាន

នីតិវិធីនៃការផ្តល់ឥណទាន គឺជាដំណើរការនៃការអនុវត្តមុខងារក្នុងការផ្តល់ឥណទានរួមមាន៖

- ការដាក់លិខិតសំណើរសុំ និង ដំណើរការនៃការបំពេញបែបបទ សំណើរសុំខ្ចីឥណទាន
- ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងវាយតម្លៃឥណទាន
- ការផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានក្នុងពេលចុះវាយតម្លៃដល់កន្លែង ជាមួយនឹងព័ត៌មានដែលទទួលបានពីការិយាល័យឥណទាន
- ការរៀបចំឯកសារខ្ចីសាច់ប្រាក់

- ការអនុម័តឥណទាន
- ការរៀបចំកិច្ចសន្យា
- ការរៀបចំបញ្ចូលទិន្នន័យ
- ការបញ្ចេញឥណទាន

## ១.៤. ដំណើរការនៃការគ្រប់គ្រងឥណទាន

### ១.៤.១. ការលើកទឹកចិត្ត

កិច្ចខិតខំប្រឹងប្រែងណាមួយដែលអនុវត្ត ដើម្បីលើកទឹកចិត្តដល់អតិថិជនឲ្យប្រើប្រាស់សេវាកម្មឥណទានកាន់តែច្រើនឡើង។ កម្មវិធីគ្រប់គ្រងការផ្តល់ឥណទាននេះ ត្រូវតែត្រួតពិនិត្យរាល់សកម្មភាពនៅក្នុងដំណើរការនៃការគ្រប់គ្រងឥណទាន ដើម្បីធានាថា អតិថិជនដែលមានគុណសម្បត្តិត្រូវបានទាក់ទាញឲ្យមកប្រើប្រាស់សេវាកម្មឥណទាន។ សម្រាប់អតិថិជនដែលធ្លាប់ប្រើប្រាស់ ឬកំពុងប្រើប្រាស់សេវាកម្មឥណទាន ដែលមានប្រវត្តិល្អនៅក្នុងការផ្តល់ឥណទានត្រូវតែបានលើកទឹកចិត្តឲ្យប្រើប្រាស់សេវាឥណទានបន្ថែមទៀតឲ្យបានញឹកញាប់[13]។

### ១.៤.២. ការពិនិត្យសំណើរពាក្យសុំលើកដំបូង

បច្ចុប្បន្ន មានអ្នកផ្តល់ឥណទានសម្រាប់អ្នកប្រើប្រាស់ជាច្រើន បានប្រើប្រព័ន្ធផ្តល់ពិន្ទុឥណទានសម្រាប់ត្រួតពិនិត្យលើសំណើរសុំឥណទានថ្មីៗ។ ចំពោះឥណទានសម្រាប់អាជីវកម្ម អ្នកផ្តល់ឥណទាន យោងតាមអនិបាតហិរញ្ញវត្ថុជាគោល សម្រាប់ផ្តល់ពិន្ទុឥណទាន (ដោយប្រើទ្រព្យសម្បត្តិ បំណុល និងប្រាក់ចំណេញសម្រាប់គណនា)។ លទ្ធផលទទួលបាន គឺសម្រាប់វាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុអាជីវកម្មដែលស្នើសុំឥណទាន។

### ១.៤.៣. ការស៊ើបអង្កេតឥណទាន

ការស៊ើបអង្កេត គឺមានការទាក់ទងទៅនឹងសកម្មភាពនៃការប្រមូលព័ត៌មានសំខាន់ៗ ដើម្បីធ្វើការសម្រេចចិត្តផ្តល់ឥណទាន។ បញ្ហាសំខាន់អ្នកគ្រប់គ្រងមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងនិយោជិក អ្នកផ្តល់ឥណទាន និងបុគ្គលិកផ្សេងៗទៀតដែលអាចបញ្ជាក់ពីលទ្ធភាពសងបំណុលរបស់អតិថិជន។

### ១.៤.៤. ការសម្រេចផ្តល់ឥណទាន

ការសម្រេចចិត្តផ្តល់ឥណទាន គឺជាសេចក្តីសម្រេចមួយដែលត្រូវបានធ្វើដោយអ្នកគ្រប់គ្រងឥណទានថា តើគួរតែផ្តល់ ឬមិនផ្តល់នូវពាក្យស្នើសុំឥណទាន។ បន្ទាប់ពីធ្វើការស៊ើបអង្កេតបានបញ្ចប់

[13]ឯក វាសនា ឆ្នាំ២០១១, ការគ្រប់គ្រងឥណទាន, ទំព័រទី ២៩-៣៤

អ្នកគ្រប់គ្រងឥណទានត្រូវសម្រេច ប្រសិនបើការសន្យាការទូទាត់សងនៅពេលក្រោយ។មានសុពលភាព ឬមានភាពប្រាកដប្រជា។ ការសម្រេចចិត្តអាចតម្រូវផងដែរនូវការកំណត់កម្រិតបន្ទាត់ឥណទាន។ កម្រិតបន្ទាត់ឥណទាន គឺជាការកំណត់នូវការចំណាយដែលមានការអនុញ្ញាតជាមុនដែលត្រូវមានការអនុញ្ញាតជាមុននិងត្រូវបានកំណត់ទៅដល់អតិថិជន។

### ១.៤.៥. ការត្រួតពិនិត្យគណនី

សកម្មភាពត្រួតពិនិត្យទាក់ទងទៅនឹងការឃ្លាំមើលទៅលើគណនី ដើម្បីបញ្ជាក់ថា បំណុលសរុបមានលក្ខណៈសមរម្យសម្រាប់អតិថិជន ។ ពេលខ្លះមួយផ្នែកនៃសកម្មភាពត្រួតពិនិត្យនេះទាមទារឲ្យអ្នកគ្រប់គ្រង គ្រប់គ្រងនូវរាល់ព័ត៌មានរបស់អតិថិជន ដើម្បីសម្រេចចិត្តថាតើគួរតែបន្ថែម ឬ កំហិតទៅលើកម្រិតបន្ទាត់ឥណទាន។

### ១.៤.៦. ការប្រមូល

សកម្មភាពប្រមូល គឺជាកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីទទួលបានការទូទាត់បំណុលរបស់អតិថិជនដែលជំពាក់តាមការកំណត់។ សកម្មភាពការប្រមូល គឺជាទិដ្ឋភាពដែលមានសារៈសំខាន់បំផុតនៃប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទាន។ កម្មវិធីប្រមូលដែលមានក្រិត្យក្រម និងកែលំអលំហូរសាច់ប្រាក់ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងបង្កើនការលក់។ សកម្មភាពទាំងនេះតម្រូវឲ្យមានការទាក់ទងអតិថិជនកាលពីមុន ដោយការបង្កើតកិច្ចព្រមព្រៀងសមហេតុផលមួយក្នុងការទូទាត់ និងធ្វើការតាមដាន ប្រសិនបើការរៀបចំបានខូចខាត។ ការស្រាវជ្រាវបានបង្ហាញថាការជំពាក់កាន់តែយូរដោយមិនបានធ្វើការទូទាត់ គឺមានការពិបាកកាន់តែខ្លាំងក្នុងការប្រមូលលុយទៅលើគណនីនោះ។

## ១.៥. ការវាយតម្លៃក្នុងការផ្ដល់ឥណទាន

មុននឹងសម្រេចផ្ដល់ឥណទានទៅឲ្យអតិថិជនស្ថាប័នត្រូវតែធ្វើការវិភាគ ឲ្យបានលម្អិត លើលក្ខខណ្ឌមួយចំនួនដូចជា ចរិកលក្ខណៈ សមត្ថភាព ដើមទុន វត្ថុបញ្ចាំ លក្ខខណ្ឌ និងសុភវិនិច្ឆ័យ។ លក្ខខណ្ឌទាំងនេះនឹងជួយដល់អ្នកគ្រប់គ្រងឥណទាន បំពេញភារកិច្ចត្រួតពិនិត្យបានឆាប់រហ័ស ដើម្បីបញ្ជាក់ ប្រសិនបើព័ត៌មានណាមួយមើលរំលង និងបញ្ជាក់ពីគុណភាពឥណទានដែលមានតម្រូវការនៃការស៊ើបអង្កេតមុននឹងធ្វើសេចក្ដីសម្រេចផ្ដល់ឥណទាន។

### ១.៥.១. ចរិកលក្ខណៈ

ចរិកលក្ខណៈ គឺជាចំនួនអវិជ្ជមានសម្រាប់បុគ្គលផ្ទាល់ ដែលទាក់ទងទៅនឹងភាពសុចរិត និងភាពខ្លាំងប្រកបដោយសីលធម៌។ កត្តាដែលរាប់បញ្ចូលទៅក្នុងការកំណត់អំពីចរិកលក្ខណៈរួមមាន

ទំលាប់ផ្ទាល់ខ្លួន និងអាកប្បកិរិយាដែលសំដែងចេញដូចជា ការផឹកស៊ី ឬការលេងល្បែងស៊ីសងជាដើម។ ចំពោះចរិកលក្ខណៈនៃឥណទាន គឺជាការសម្តែងចេញនូវចេតនាដ៏ល្អរបស់អ្នកប្រើប្រាស់ឥណទានដោយស្ម័គ្រចិត្តក្នុងការទូទាត់សំណងរបស់ពួកគាត់តាមកិច្ចសន្យា។

**១.៥.២. សមត្ថភាព**

សមត្ថភាព គឺជាលទ្ធភាពរបស់អ្នកស្នើសុំឥណទាន បញ្ជាក់អំពីកាតព្វកិច្ចសងតាមពេលកំណត់នៃកិច្ចសន្យា។ ការវាយតម្លៃទៅលើសមត្ថភាពនៃអ្នកស្នើសុំ ជាទូទៅវាជាប់ទាក់ទងនឹងការស៊ើបអង្កេតទៅលើចំណូល ការងារ ការចំណាយផ្សេងៗ និងភាពជំពាក់បំណុលគេ។ ចំណូលរបស់អ្នកស្នើសុំត្រូវតែមាននិរន្តភាព និងអាចព្យាករណ៍បាន។ សមត្ថភាពត្រូវបានទទួលរងការគំរាមកំហែងប្រសិនបើបុគ្គលម្នាក់ៗឆ្ពោះទៅរកភាពអត់ការងារធ្វើ ឬចំណូលត្រូវបានកាត់បន្ថយ។

**១.៥.៣. ដើមទុន**

ដើមទុន គឺជាភាពខ្លាំងខាងផ្នែកហិរញ្ញវត្ថុរបស់អ្នកស្នើសុំឥណទាន ជាទូទៅបានបង្ហាញពីទ្រព្យបំរុងរបស់អ្នកស្នើសុំឥណទាន។ ដើមទុនទាំងនោះអាចជាទ្រព្យសកម្មរូបីដែលមានដូចជាសមតុល្យគណនីសំចៃ ឬទ្រព្យសកម្មអរូបីដែលមានដូចជា សមត្ថភាពស្វែងរកការងារធ្វើផ្សេងៗបានរហ័ស ពីព្រោះគេមានការយល់ដឹង និងមានជំនាញពិសេសរបស់គេ។ ទ្រព្យសម្បត្តិទាំងនេះអាចផ្តល់ភាពងាយស្រួលដល់អ្នកស្នើសុំក្នុងករណីខ្លះដើម្បីជាការពឹងពាក់ប្រសិនបើហិរញ្ញវត្ថុមានភាពមិនអនុគ្រោះ។

**១.៥.៤. វត្ថុបញ្ចាំ**

វត្ថុបញ្ចាំ គឺទ្រព្យសម្បត្តិដែលអ្នកប្រើប្រាស់ឥណទានផ្តល់ឲ្យអ្នកផ្តល់ឥណទាន ដើម្បីធានាលើកម្ចី ឬជាកាតព្វកិច្ចឥណទាន និងដោះស្រាយបញ្ហាឥណទានដែលមិនបានទូទាត់សំណងតាមកិច្ចសន្យា ។ ដូច្នេះមន្ត្រីឥណទានត្រូវតែមានការប្រុងប្រយ័ត្នក្នុងការវាយតម្លៃវត្ថុបញ្ចាំ និងត្រូវដឹងថា តើវត្ថុបញ្ចាំទាំងនោះមានគុណភាពគ្រប់គ្រាន់ដែរឬទេ?

**១.៥.៥. លក្ខខណ្ឌ**

លក្ខខណ្ឌ គឺជាប្រភេទនៃការវិភាគឥណទាន ដើម្បីចង់ដឹងថាតើអ្នកស្នើសុំឥណទានមានទំនាក់ទំនងយ៉ាងណាជាមួយនឹងប្រព័ន្ធសេដ្ឋកិច្ច និងមើលថាតើព្រឹត្តិការណ៍សេដ្ឋកិច្ចនឹងមានឥទ្ធិពលកម្រិតណាចំពោះលទ្ធភាពសងបំណុលរបស់អ្នកប្រើប្រាស់ឥណទាន។ លក្ខខណ្ឌ គឺផ្តោតទៅលើកត្តាខាងក្រៅ និងកត្តាខាងក្នុង ដែលជះឥទ្ធិពលទៅលើសមត្ថភាពសងបំណុលរបស់អ្នកស្នើសុំឥណទាន។ កត្តាខាងក្រៅរួមមាន ស្ថានភាពសេដ្ឋកិច្ច ច្បាប់ពន្ធ

ការផ្លាស់ប្តូរច្បាប់ ភាពជឿនលឿននៃបច្ចេកវិទ្យា ការគំរាមកំហែងពីសង្គ្រាម និងគ្រោះធម្មជាតិជាដើម។ កត្តាខាងក្នុងរួមមានលក្ខខណ្ឌកិច្ចសន្យាឥណទាន គោលការណ៍ឥណទាន គម្រោងថវិកាឥណទាន និងសមត្ថភាពជំនាញរបស់បុគ្គលិក ឬអ្នកបច្ចេកទេសក្នុងការត្រួតពិនិត្យឥណទាន។

**១.៥.៦. សុភវិនិច្ឆ័យ**

សុភវិនិច្ឆ័យ គឺជាការវាយតម្លៃចុងក្រោយ និងជាឧបករណ៍វិភាគឥណទានមួយបន្ទាប់ពីគណនីមួយបានបញ្ជាក់ថា នឹងក្លាយជាបំណុលពិបាកទារ។ អ្នកវិភាគឥណទានបញ្ជាក់ថា ការប្រើការវិនិច្ឆ័យ ដើម្បីជៀសវាងការទំនាក់ទំនងឥណទាននៅលើទីកន្លែងតែមួយ។ ជាធម្មតាការប្រៀបធៀប ការអង្កេត និងការគណនាអាចនឹងបង្ហាញថា កម្ចី ឬគណនីឥណទាន គឺមិនគួរផ្តល់ឲ្យ។ ពេលខ្លះវាគឺជាការទទួលខុសត្រូវរបស់អ្នកផ្តល់ឥណទាន ដើម្បីកំណត់ថាគួរ ឬ មិនគួរបន្តផ្តល់ឥណទាន។

**១.៦. ហានិភ័យឥណទាន**

**១.៦.១. និយមន័យ**

ហានិភ័យឥណទាន គឺជាកម្រិតនៃគ្រោះថ្នាក់ចំពោះប្រាក់កម្ចីរបស់ធនាគារដោយទទួលរងនូវកា ការខាតបង់ដោយសារអតិថិជនរបស់ខ្លួនមិនសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន ឬសងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើម និងការប្រាក់។ ហានិភ័យនេះជាហានិភ័យមួយប្រភេទដែលធនាគារបានយកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចជម្រុញឲ្យធនាគារក្ស័យធនបាន ដូចនេះមុននឹងសម្រេចចិត្តផ្តល់ ធនាគារតែងតែសិក្សាទៅលើហានិភ័យឥណទានជាចម្បង រហូតទាល់តែធនាគារយល់ឃើញថា គ្មានហានិភ័យ ឬហានិភ័យទាបទើបធនាគារផ្តល់កម្ចី[14]។

**១.៦.២. មូលហេតុដែលនាំឲ្យមានហានិភ័យឥណទាន**

មានកត្តាបីយ៉ាងដែលនាំឲ្យមានហានិភ័យឥណទាន គឺកត្តាអតិថិជន ធនាគារ និង សេដ្ឋកិច្ចសង្គម និងធម្មជាតិ។

**១.៦.២.១. កត្តាអតិថិជន**

- ការព្យាករណ៍ ឬការវាយតម្លៃលើការវិនិយោគនៅទាប គំនិតក្នុងការវិនិយោគនៅស្ទើមិនទាន់មានសមត្ថភាពគ្រប់គ្រាន់

[14]ងួន ហេង ឆ្នាំ២០១៤, ធនាគារ និងរូបិយវត្ថុ ទំព័រ៥៥

- មិនសូវមានការពិចារណាឲ្យបានស៊ីជម្រៅទៅលើការវិនិយោគណាមួយ ឬចូលចិត្តការវិនិយោគណាដែលមានប្រាក់ចំណេញច្រើន
- អាចត្រូវដៃគូ ឬអ្នកវិនិយោគផ្សេងទៀតបោកប្រាស់
- ការប្រើប្រាស់លុយខុសគោលដៅ
- គ្រួសារ ឬសមាជិកណាមួយក្នុងគ្រួសារត្រូវការលុយក្នុងការមើលជម្ងឺ
- អតិថិជនខ្លះមានគោលបំណងមិនសងប្រាក់ដល់ធនាគារ ទោះបីជាមានលទ្ធភាពសងក៏ដោយ។

**១.៦.២.២. កត្តាធនាគារ**

- បុគ្គលិកពុំមានសមត្ថភាពគ្រប់គ្រាន់ដើម្បីវាយតម្លៃអតិថិជន ឬការវិនិច្ឆ័យមិនបានត្រឹមត្រូវ
- បុគ្គលិកមិនមានភាពស្មោះត្រង់
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន ត្រួតពិនិត្យបំណុលទាន់ពេលវេលា
- បុគ្គលិកមានចេតនាធ្វើឲ្យមានកំហុស

**១.៦.២.៣. កត្តាសេដ្ឋកិច្ច សង្គម និងគ្រោះធម្មជាតិ**

- សេដ្ឋកិច្ច៖ កាលណាមានវិបត្តិសេដ្ឋកិច្ចកើតឡើង នាំឲ្យបណ្តាក្រុមហ៊ុនសហគ្រាសប្រឈមមុខនឹងការក្ស័យធន ព្រោះថាតម្រូវការអតិថិជន មានការធ្លាក់ចុះដែលជាមូលហេតុធ្វើឲ្យចំណូលផ្ទាល់ខ្លួន និងចំណូលក្រុមហ៊ុនធ្លាក់ចុះ។ ដូច្នេះក្រុមហ៊ុនពុំមានលទ្ធភាពសងចំណុលធនាគារ។
- សង្គម៖ មានដូចជាសង្គ្រាម មានការប្រែប្រួលនៃសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល នយោបាយ។
- គ្រោះធម្មជាតិ៖ ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ផ្ទះ នាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងដោយសារអាជីវកម្ម ឬមុខរបរត្រូវបានផ្អាកដំណើរការ[15]។

## ១.៦.៣. យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យឥណទាន

### ១.៦.៣.១. វាយតម្លៃអតិថិជនឲ្យបានត្រឹមត្រូវ

ត្រូវដឹងឲ្យច្បាស់ពីគោលការណ៍នៃការសុំខ្ចី៖

[15]សុខ ចំរើន និង ឡេង សុភក្រ្គ ឆ្នាំ២០១៣,ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ទំព័រ ៥៦-៥៧

- ពិនិត្យមើលអាជីវកម្ម
- វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
- ពិនិត្យលើប្រវត្តិរូបរបស់អ្នកខ្ចី
- ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា
- ផ្តល់យោបល់ក្នុងករណីផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មរបស់អតិថិជន

#### ១.៦.៣.២. ពង្រឹងសមត្ថភាពបុគ្គលិកឲ្យមានសមត្ថភាព

- ជ្រើសរើសបុគ្គលិកដែលមានជំនាញខាងឥណទាន
- ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកជាការចាំបាច់
- ដាក់ទោសលើបុគ្គលិកដែលមានកំហុស
- លើកទឹកចិត្តដល់បុគ្គលិកដែលធ្វើការបានល្អ

## ១.៧. ដំណោះស្រាយបំណុលមានបញ្ហា

បំណុលដែលបណ្តាលឲ្យមានបញ្ហា គឺនៅពេលដែលអតិថិជនខ្វះសាច់ប្រាក់ ឬមិនមានប្រាក់គ្រប់គ្រាន់ សម្រាប់ធ្វើការទូទាត់សងនូវការប្រាក់ និងប្រាក់ដើមនៃបំណុល។ នៅពេលដែលមានបញ្ហាកើតឡើង នោះនាំឲ្យជួបវិបត្តិផ្ទៃក្នុង និង ខាងក្រៅក៏ចាប់ផ្តើមកើតមានដែរ។ ភ្នាក់ងារឥណទានត្រូវតែស្វែងយល់អំពីមូលហេតុនៃវិបត្តិឲ្យទាន់ពេលវេលា និងរិះរកវិធីដោះស្រាយបញ្ហាឲ្យបានទាន់ពេលវេលានិងធ្វើការកែប្រែវា។ ការប្រាស្រ័យទាក់ទងរវាងភ្នាក់ងារឥណទាន និងអតិថិជនកាន់តែជិតស្និទ្ធ ហើយព័ត៌មានដែលអាចប្រើបានចំពោះស្ថានភាព កូនបំណុលនោះកាន់តែច្បាស់ នៅក្នុងដំណើរការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាអ្នកទីមួយដែលគេឃើញ អត្តសញ្ញាណនៃឥណទានខិតខំទប់ទល់ការពារសុវត្ថិភាព នៃប្រាក់ឲ្យខ្ចីយ៉ាងណាក៏ដោយ ក៏ជៀសមិនផុតពីបញ្ហាដែលកើតឡើងពីប្រាក់ឲ្យខ្ចីនេះ។ម្យ៉ាងទៀត មានការត្រួតពិនិត្យលើករណីរបស់អតិថិជនដូចខាងក្រោមនេះ

-ការពន្យាពេលទទួលព័ត៌មានហរិញ្ញវត្ថុ ជាពិសេសបើកិច្ចសន្យានៃកូនបំណុលតម្រូវឲ្យបញ្ជូនឯកសារទាំងអស់នោះទាន់ពេលវេលា។

-ការផ្លាស់ប្តូរយ៉ាងលឿននៅក្នុងផែនការពាណិជ្ជកម្មមូលដ្ឋានរបស់អតិថិជន និងការផ្លាស់ប្តូរដែលមានការសង្ឃឹមទុននៃក្រុមប្រឹក្សារបស់ក្រុមហ៊ុន និងនិន្នាការមិនល្អនៃទីផ្សាររបស់អតិថិជន (ការលក់ធ្លាក់ចុះការប្រាក់ ធ្វើឲ្យប្រាក់ចំណេញធ្លាក់ចុះ)។

-មានការខ្ចីបន្ថែមពីគ្រឹះស្ថានហរិញ្ញវត្ថុផ្សេងៗទៀតដូចជា បំណុលរយៈពេលខ្ចី ការសុំបង្កើត

កាលអវសាន្ត កូនបំណុលប្រើប្រាស់បំណុលរយៈពេលខ្លី និងការទិញទំនិញរយៈពេលវែង សកម្មភាព និងសញ្ញាព្រមាន ទាំងនេះគួរតែធ្វើការស៊ើបអង្កេតយ៉ាងប្រុងប្រយ័ត្ន។

### ១.៧.១. វិធានការទប់ស្កាត់បំណុលមានបញ្ហា

ការស្វែងយល់ពី អត្តសញ្ញាណទាន់ពេលវេលា នៃការលំបាករបស់កូនបំណុលធ្វើឲ្យគ្រឹះស្ថានហិរញ្ញវត្ថុមានពេលប៉ាន់ស្មានសកម្មភាពការពិត និងបង្កើនយុទ្ធសាស្ត្រទប់ទល់បញ្ហាភ្លាមៗ។ នៅពេលដែលភ្នាក់ងារឥណទានស្វែងយល់អំពីឥណទាន ដែលកាន់តែធ្ងន់ធ្ងររបស់កូនបំណុលរួចគួរពិនិត្យនិងចាត់វិធានការតាមចំណុចដូចខាងក្រោម៖

-វិភាគបញ្ហារបស់កូនបំណុល

-ពិគ្រោះយោបល់ជាមួយផ្នែកណាមួយនៃគ្រឹះស្ថានហិរញ្ញវត្ថុដែលមានជំនាញខាងផ្នែកនេះ

-សំណូមពរការពន្យាពេល ការទូទាត់ការប្រាក់ ប្រសិនបើចាំបាច់

-ប្រមូលព័ត៌មានសរុប ដែលពាក់ព័ន្ធនិងគ្រឹះស្ថានហិរញ្ញវត្ថុ និងកូនបំណុល

-ត្រួតពិនិត្យសកម្មភាពគណនីសម្រាប់បើកឥណទានវិបារូបចំណាំ និងវត្ថុបញ្ចាំ។

### ១.៧.២. ការដោះស្រាយបំណុលមានបញ្ហា

- ត្រូវចាំពីគោលបំណងនៃការធ្វើឥណទាន គឺបង្កើនឪកាសសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការប្រមូលបំណុល

-រកឲ្យឃើញ និងរាយការណ៍ភ្លាមៗអំពីបញ្ហាដែលកើតមានចំពោះប្រាក់កម្ចី គឺជាការសំខាន់ប្រសិនបើមានការយឺតយ៉ាវ និងធ្វើឲ្យមានបញ្ហាកាន់តែលំបាក។

-បែងចែកការទទួលខុសត្រូវចំពោះការធ្វើគម្រោងឥណទាន ឲ្យដាច់ចេញពីមុខងារឲ្យខ្ចី ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ការទទួលការប្រាក់ណាមួយដែលអាចកើតឡើងចំពោះភ្នាក់ងារឥណទាន។

- អ្នកឯកទេសសំខាន់ៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលទទួលបន្ទុកខាងផ្នែកធ្វើគម្រោងគប្បីពិភាក្សាភ្លាមៗជាមួយអតិថិជនដែលមានបញ្ហាស្តីពីវិធានការផ្សេងៗដូចជា ការកាត់ចំណាយ ការបង្កើនលំហូរសាច់ប្រាក់ ការកែលំអការងារគ្រប់គ្រងជាដើម។ ធ្វើផែនការអនុវត្តក្រោយពេលបានកំណត់ហានិភ័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងនៅពេលមានឯកសារគ្រប់គ្រាន់។

- ធ្វើការប៉ាន់ស្មានពីប្រភេទ ដែលអាចប្រើប្រាស់ក្នុងការប្រមូលបំណុល

-ក្នុងករណីក្រុមហ៊ុនជំនួញ បុគ្គលិកឥណទានត្រូវវាយតម្លៃគុណភាព សមត្ថភាព និងភាពស្មោះ

ត្រង់នៃការគ្រប់គ្រងបច្ចុប្បន្ន ការចុះទៅផ្ទាល់ដល់ទីកន្លែងដើម្បីវាយតម្លៃទ្រព្យសម្បត្តិ និង ប្រតិបត្តិការរបស់អ្នកខ្ចីប្រាក់។

- បុគ្គលិកទទួលបន្ទុកត្រូវពិចារណារកមធ្យោបាយផ្សេងៗ ដើម្បីដោះស្រាយបំណុលដែលមានបញ្ហាដូចជា ការធ្វើកិច្ចសន្យាថ្មីបណ្តោះអាសន្នមួយប្រសិនបើដោះស្រាយក្នុងរយៈពេលខ្លី។

# ជំពូកទី២

# ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

## ២.១. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

ការចាប់កំណើតរបស់អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូអិលធីឌីវិវត្តមកពីការធ្វើអន្តរាគមន៍ឥណទានខ្នាតតូចរបស់អង្គការ Concern Worldwide នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ដោយសារប្រតិបត្តិការមានការរីកចម្រើនក្នុងឆ្នាំ២០០២ អង្គការ Concern បានបង្កើតក្រុមហ៊ុន មីក្រូហិរញ្ញវត្ថុដាច់ដោយឡែកដែលបានប្រែក្លាចទៅជា អេ អឹម ខេ ។ នៅត្រឹមឆ្នាំ២០០៣ អេ អឹម ខេ បានធ្វើប្រតិបត្តិការដោយឯករាជ្យពីអង្គការ Concern ហើយបន្ទាប់មកទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅឆ្នាំ២០០៤។

នៅឆ្នាំ២០០៥ អេ អឹម ខេ ទទួលបានប្រាក់ចំណេញពីប្រតិបត្តិការដំបូងរបស់ខ្លួន និងទទួលបានប្រាក់កម្ចីពីប្រភពខាងក្រៅព្រមទាំងបង្កើតយន្តការគ្រប់គ្រងការងារសង្គមផងដែរ។ នៅឆ្នាំបន្តបន្ទាប់ អេ អឹម ខេ ទទួលបាននូវការរីកចម្រើនយ៉ាងឆាប់រហ័សចំពោះសេវាប្រាក់កម្ចីដ៏សំខាន់ពង្រីកបណ្តាញសាខាប្រតិបត្តិការនៅទូទាំងប្រទេស។

នៅឆ្នាំ២០១០ កំណែទម្រង់ជាយុទ្ធសាស្រ្តត្រូវបានចាប់ផ្តើមអនុវត្តដោយបានធ្វើការផ្លាស់ប្តូរ អេ អឹម ខេ ពីឥណទានជនបទតែមួយមុខទៅជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដ៏សម្បូរបែប។ យុទ្ធសាស្រ្តនេះត្រូវបានត្រូសត្រាយពីតម្រូវការក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុជាច្រើនប្រភេទទៅដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងគោលបំណងធ្វើឲ្យជីវភាពរបស់ពួកគេបានប្រសើរឡើង។

ការទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់សន្សំពីសាធារណជន(MDI) ក្នុង ២០១០ បានដើរតួនាទីយ៉ាងសំខាន់ចំពោះដំណើរការនេះ។ វាបានជំរុញឲ្យ អេ អឹម ខេ ផ្តល់នូវផលិតផល និងបណ្តាញសេវាជាច្រើនទៀត។ ផលិតផលសន្សំបានដាក់ឲ្យដំណើរការនៅគ្រប់សាខាទូទាំងប្រទេសត្រឹមពាក់កណ្តាលឆ្នាំ២០១១ ជាមួយនិងសេវាផ្ទេរប្រាក់ក្នុងស្រុក ដែលបានដាក់ឲ្យដំណើរការនៅក្នុងខែកក្កដា ឆ្នាំ២០១១។ សេវាកម្មទាំងពីរនេះត្រូវបានពង្រីកទៅគ្រន់សាខា និង អនុសាខាទាំង ១១៣ របស់ អេ អឹម ខេ ក្នុងអំឡុងឆ្នាំ ២០១២។ អេ អឹម ខេ ក៏ចាប់ផ្តើមដាក់សាកល្បងរយៈពេលមួយឆ្នាំ នូវភ្នាក់ងារធនាគារចល័តពីឆ្នាំ ២០១១ ដល់ ២០១២។

នៅឆ្នាំ២០១៣ អេ អឹម ខេ ក៏បានដាក់ឲ្យដំណើរការម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ (AMKs/CDMs) ជាបណ្តាញប្រតិបត្តិការបន្ថែមចំពោះអតិថិជនរបស់ខ្លួនដើម្បីឲ្យកាន់តែមានភាពងាយស្រួល និងប្រសើរឡើងក្នុងការប្រើប្រាស់សេវាប្រាក់សន្សំរបស់ខ្លួនផងដែរ។ អេ អឹម

ខេ ក៏បាបន្ថែមម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ (AMKs/CDMs) ចំនួន ៥៤ គ្រឿងទៀតនៅតាមការិយាល័យសាខាទូទាំងប្រទេសនាបំណាច់ឆ្នាំ ២០១៥។

លើសពីនេះទៀត អ្នកនិពន្ធជនជាតិអង់គ្លេសបានសរសេរសៀវភៅមួយ ស្តីពីដំណើរការអាជីវកម្មជោគជ័យរបស់ អេ អឹម ខេ ផងដែរ។

តាមរយៈប្រវត្តិរបស់ខ្លួន អេ អឹម ខេ បានប្តេជ្ញាចិត្តក្នុងការបំពេញការងារសង្គមឲ្យបានពេញលេញ។ អេ អឹម ខេ បានបង្កើតក្របខណ្ឌការគ្រប់គ្រងកិច្ចការសង្គមមួយដ៏ទូលំទូលាយដើម្បីធានាគ្រឹះស្ថាននេះនៅតែផ្តោតលើបេសកកម្មរបស់ខ្លួន ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន។ បច្ចុប្បន្ន អេ អឹម ខេ មានបុគ្គលសរុបចំនួន ២.១២៦ នាក់បម្រើអតិថិជនចំនួន ៤៧៧,៦៣៦ នាក់ក្នុងភូមិចំនួន ១២.៣៩៤ ទូទាំងប្រទេស។ វិសាលភាពនៃប្រតិបត្តិការនេះស្មើនឹង ៨៨% នៃចំនួនភូមិទាំងអស់។

## ២.២. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ជាសាខាមួយក្នុងចំណោមសាខាដទៃទៀត ដែលអាចបម្រើសេវាកម្មជូនអតិថិជន និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកប្រធានសាខា និងរចនាសម្ព័ន្ធគ្រប់គ្រងទាំងឡាយតាមនាយកដ្ឋានជំនាញរបស់ការិយាល័យកណ្តាល។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា បានចាប់បដិសន្ធិឡើងដំបូងនៅ ថ្ងៃទី០១ ខែ១០ ឆ្នាំ២០១១ ។

## ២.៣. អត្តសញ្ញាណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

### ២.៣.១. រូបសញ្ញា

### ២.៣.២. អត្ថន័យនៃរូបសញ្ញា

- Amk = Angkor Mikroheranhvatho Kampuchea
- អេ អឹម ខេ < អង្គរ មីក្រូហិរញ្ញវត្ថុ កម្ពុជា>
- និមិត្តសញ្ញារូបគូរស្រូវ តំណាងឲ្យទស្សនៈវិស័យ និង បេសកកម្ម របស់ អេ អឹម ខេ គឺជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើនក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់សេវា មីក្រូហិរញ្ញវត្ថុសមស្រប និងបិតថេរ។

## ២.៤. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

### ២.៤.១. ទីតាំងសាខាទូទាំង២៥ខេត្ត-ក្រុង

អេ អឹម ខេ តែងតែធ្វើដំណើរទៅមុខ បន្តទៀតដើម្បីនាំមកជូនលោកអ្នក នូវប្រតិបត្តិការកាន់តែងាយស្រួលជាងមុន ហេតុនេះហើយយើងបានបង្កើតនូវបណ្តាញ សាខាប្រតិបត្តិការដ៏ទូលំទូលាយពេញក្នុងខេត្ត ក្រុងជាច្រើនរបស់ប្រទេសកម្ពុជា។ គិតមកសល់ត្រឹមឆ្នាំ ២០១៩ អេ អឹម ខេ ធ្វើប្រតិបត្តិការ នៅតាមបណ្តាញសាខាចំនួន ១៥០ ការិយាល័យនៅទូទាំងរាជធានី/ខេត្តចំនួន ២៥ ដែលទាំងនេះមានន័យថាដរាបណាមានអតិថិជននៅទីណា នោះប្រាកដជាមានបុគ្គលិករបស់ អេ អឹម ខេ នៅជិតលោកអ្នកដែរ។ បណ្តាញប្រតិបត្តិការ អេ អឹម ខេ មានទីតាំងស្ថិតនៅកន្លែងងារស្រួលសម្រាប់អតិថិជន និងមានសេវាដ៏ប្រសើរដល់ទីកន្លែង។



## ២.៤.២. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា មានទីតាំងស្ថិតនៅផ្ទះលេខ០៨ ផ្លូវសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

Mr. Nhim Sokphirun

Mobile: +885 (0) 98 333 170

Email: sokphirun.nhim@amkcambodoi.com



# ២.៥. ភាគហ៊ុនិក ដើមទុន និងប្រភពហិរញ្ញវត្ថុ

## ២.៥.១. ភាគហ៊ុនិក ដើមទុន

ភាគទុនិករបស់ អេ អឹម ខេ ជាអ្នកចង្អុលបង្ហាញទិសដ៏សំខាន់បំផុតសម្រាប់ដឹកនាំគ្រឹះស្ថានទាំងមូល ឈានទៅសម្រេចបានការធ្វើឲ្យមានតុល្យភាពរវាងគោលដៅសង្គម និងគោលដៅហិរញ្ញវត្ថុ។ ពួកគេបន្តជំរុញឲ្យមានប្រព័ន្ធវាយតម្លៃនៃ អេ អឹម ខេ ក៏ដូចជាការរក្សាឲ្យបាននូវប្រាក់ចំណេញ និងចំណុចសំខាន់របស់អាជីវកម្ម នោះជាតម្លៃដែលប្រែក្លាយជាដំណោះស្រាយ និងយុទ្ធសាស្ត្រ ពីប្រាក់លើកទឹកចិត្តដល់បុគ្គលិក រហូតដល់ការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់អតិថិជន។ ភាគទុនិករបស់ អេ អឹម ខេ បច្ចុប្បន្នរួមមាន៖

- The Shanghai Commercial & Savings Bank, Ltd. (SCSB)
- Agora Microfinance N.V. (AMNV)
- សមាគមបុគ្គលិក អេ អឹម ខេ (AMK-SA)

ភាគទុនិករបស់ អេ អឹម ខេ បានតែងតាំង ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវចំពោះការងារអភិបាលកិច្ចរួម និងទិសដៅយុទ្ធសាស្ត្រសម្រាប់គ្រឹះស្ថាន។ ក្រុមប្រឹក្សាភិបាលដែលមានសមាជិក ៨ រូបមានជំនាញផ្សេងៗ គ្នារួមមាន ផ្នែកសវនកម្ម ច្បាប់កម្ពុជា គ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុ ការអភិវឌ្ឍធនធានមនុស្ស មីក្រូហិរញ្ញវត្ថុ និងមានបទពិសោធន៍យូរឆ្នាំក្នុងវិស័យធនាគារពាណិជ្ជ។ សព្វថ្ងៃនេះ អភិបាលកិច្ច អេ អឹម ខេ មានសមាជិក ដែលមិនមែនជាផ្នែកប្រតិបត្តិចំនួន ៨ រូបបន្ថែមពីលើ ប្រធាននាយកប្រតិបត្តិ (CEO) ដែលជាតំណាងគ្រប់គ្រងក្នុងក្រុមប្រឹក្សាភិបាល។

ក្នុងនោះផងដែរ មានគណៈកម្មាធិការចំនួនប្រាំ ដែលរាយការណ៍ផ្ទាល់ទៅកាន់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនីមួយៗ មានសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ និងអ្នកជំនាញពីខាងក្រៅម្នាក់។ គណៈកម្មាធិការទាំងនេះរួមមាន៖

**១. គណៈកម្មាធិការវាយតម្លៃការតែងតាំង និងអភិបាលកិច្ច (RNCG)**

គណៈកម្មាធិការនេះមានភារកិច្ច ត្រួតពិនិត្យលើការវាយតម្លៃបុគ្គលិករបស់គ្រឹះស្ថាន និងធានាថាបុគ្គលិកទាំងអស់ ទទួលប្រាក់លើកទឹកចិត្តស្មើៗគ្នា ចំពោះការរួមចំណែករបស់ពួកគេក្នុងការបំពេញការងារឲ្យគ្រឹះស្ថាន។ គណៈកម្មាធិការនេះ ក៏ទទួលខុសត្រូវ ជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងសមាជិកក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ ផងដែរ។ គណៈកម្មាធិការនេះក៏មានភារកិច្ចណែនាំសមាជិកថ្មីៗ រៀបសេចក្តីសង្ខេប ដើម្បីឲ្យក្រុមប្រឹក្សាភិបាលឲ្យទទួលបានព័ត៌មានទាន់ពេលវេលា លើការអភិវឌ្ឍផ្នែកអភិបាលកិច្ចគ្រឹះស្ថាន ធ្វើបច្ចុប្បន្នភាព

ដល់ក្រុមប្រឹក្សាភិបាល ពីតួនាទី របស់ក្រុមប្រឹក្សាភិបាល និង ការទទួលខុសត្រូវរបស់ពួកគេ ឧទាហរណ៍ដូចជា កាតព្វកិច្ចផ្លូវច្បាប់ជាដើម។ ទាក់ទងនឹងអភិបាលកិច្ចគ្រឹះស្ថាន គណៈកម្មាធិការនេះ ធានាថាក្រុមប្រឹក្សាភិបាលបានបំពេញការងារបានយ៉ាងល្អបំផុត ដោយធានាបាននូវប្រសិទ្ធភាពទាំងមូលនៃក្រុមប្រឹក្សាភិបាល និង អនុវត្ត ឬ សម្របសម្រួលការវាយតម្លៃខ្លួនឯង និង ការវាយតម្លៃគ្នាទៅវិញទៅមក ក្នុងក្រុមប្រឹក្សាភិបាលនៅអំឡុងពេលជាក់លាក់ណាមួយ។

**២. គណៈកម្មាធិការការងារសង្គម (SPC)**

គណៈកម្មាធិការនេះ មានភារកិច្ចទទួលខុសត្រូវ ក្នុងការផ្តល់យោបល់ ដល់ក្រុមប្រឹក្សាភិបាល លើការងាររបស់ អេ អឹម ខេ ដែលទាក់ទងនឹងសង្គម។ វិធីសាស្ត្រនៃការវិភាគ និងការវាយការណ៍ ព្រមទាំងក្របខណ្ឌទាក់ទងនឹងការងារសង្គម។ គណៈកម្មាធិការនេះ មានភារកិច្ចក្នុងការផ្តល់ព័ត៌មានទាន់ពេលវេលា ដល់ក្រុមប្រឹក្សាភិបាល និង ថ្នាក់ដឹកនាំជាន់ខ្ពស់ ទៅលើបញ្ហានៃការងារសង្គមដែលបានលេចឡើង និងការអភិវឌ្ឍន៍ជាសាកល ព្រមទាំងការសម្រេចចិត្តថាតើ លទ្ធផលទទួលបានពីដំណើរការស្រាវជ្រាវពីអតិថិជនមានលក្ខណៈត្រឹមត្រូវបានដល់កម្រិតណា ។

**៣. គណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុ (AFC)**

គណៈកម្មាធិការនេះមានភារកិច្ចទទួលខុសត្រូវ សម្រាប់ការធានាសុច្ចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន នៅក្នុងការអនុវត្តការរាយការណ៍ និងការបង្ហាញព័ត៌មានដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងធនាគារជាតិនៃកម្ពុជា ត្រូវមានភាពច្បាស់លាស់ ត្រឹមត្រូវ និងទុកចិត្តបាន ។ គណៈកម្មាធិការនេះក៏មាន ភារកិច្ចអនុវត្តនូវកិច្ចការមួយចំនួនដូចខាងក្រោមនេះផងដែរៈ

- ត្រួតពិនិត្យនូវភាពត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថាន ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីសុំការអុនម័តពីភាគទុនិក ស្តីពីការតែងតាំងសវនករខាងក្រៅ។
- ពិនិត្យនិងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត លើរបាយការណ៍ សវនកម្មហិរញ្ញវត្ថុ។
- ពិនិត្យឡើងវិញនូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់គ្រឹះស្ថាន។
- តាមដាននិងត្រួតពិនិត្យឡើងវិញនូវប្រសិទ្ធិភាពនៃមុខងារសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន (នាយកដ្ឋានសវនកម្មផ្ទៃក្នុង)
- តាមដាន និងការពិនិត្យឡើងវិញនូវឯករាជ្យភាព វត្ថុបំណងនិងប្រសិទ្ធិភាពរបស់សវនករខាងក្រៅ

**៤. គណៈកម្មាធិការគ្រប់គ្រងហានិភ័យថ្នាក់ក្រុមប្រឹក្សាភិបាល (BRC)**

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង អេ អឹម ខេ មានការជឿជាក់យ៉ាងមុតមាំថា ការគ្រប់គ្រងហានិភ័យពិតជាមានសារៈសំខាន់ណាស់ធ្វើឲ្យ អេ អឹម ខេ ទទួលបានជោគជ័យ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយ។ ទស្សនៈវិទ្យារបស់យើង គឺធានាថាហានិភ័យទាំងឡាយដែលយើងមាន អាចជួយឲ្យយើងសម្រេចបាននូវផែនការយុទ្ធសាស្ត្រអាជីវកម្ម និងគោលដៅរបស់គ្រឹះស្ថានដោយរក្សារបាននៅក្នុងកម្រិតដែលអាចទទួលយកបាន ដែលអាចឲ្យយើងការពារដើមទុន និងអាចថ្លឹងថ្លែងបានយ៉ាងត្រឹមត្រូវរវាងហានិភ័យ និងប្រាក់ចំណេញ។

គណៈកម្មាធិការហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល (BRC) មានតួនាទីត្រួតពិនិត្យការគ្រប់គ្រងហានិភ័យគ្រឹះស្ថានរួមមាន ហានិភ័យខាងក្នុង និងខាងក្រៅមានដូចជា ប្រតិបត្តិការហិញ្ញវត្ថុ ឥណទានការប្រតិបត្តិតាម និងកេរ្តិ៍ឈ្មោះជាដើម ក្នុងចំណោមគ្រឹះស្ថានផ្សេងទៀត។

**៥. គណៈកម្មាធិការ ទ្រព្យសកម្ម និងបំណុល កម្រិតក្រុមប្រឹក្សាភិបាល (Board ALCO)**

គណៈកម្មាធិការនេះ ត្រួតពិនិត្យជាយុទ្ធសាស្ត្រនៃការគ្រង់គ្រងតារាងតុល្យការរបស់គ្រឹះស្ថាន ដល់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការ ជាអ្នកផ្តល់មតិយោបល់ និងគំនិតជាយុទ្ធសាស្ត្រ ចំពោះដំណើរការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ហើយដើរតួនាទីជាអង្គភាពក្នុងការអនុម័តប្រភពទុន ហានិភ័យ និង គោលនយោបាយគ្រប់គ្រងទ្រព្យសកម្ម និងបំណុល។

ទ្រព្យសកម្ម និង បំណុល អេ អឹម ខេ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមួយ ដើរក្នុងការបង្កើនតម្លៃរបស់ភាគទុនិកដល់កម្រិតអតិបរមា ដើម្បីពង្រឹងការរីកចម្រើន និង ប្រាក់ចំណេញប្រកបដោយនិរន្តភាព ធ្វើឲ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងដើមទុន និងការពារគ្រឹះស្ថានពីហានិភ័យហិរញ្ញវត្ថុហួសកម្រិតណាមួយ ដែលកើតចេញពីបំលាស់ប្តូរ នៅក្នុងបរិយាកាសទីផ្សារ។

គណៈកម្មាធិការ ទ្រព្យសកម្ម និង បំណុល បានគិតគូពីការគ្រប់គ្រងបំណុល ការប្រមូលមូលនិធិ និង ដើមទុន អត្រាប្តូរប្រាក់បរទេស និង ហានិភ័យ ដែលបណ្តាលមកពីភាគីផ្សេងទៀត ការផ្លាស់ប្តូរ ផ្នែកផលិតផល និង ការរៀបចំគម្រោងថវិការប្រចាំឆ្នាំ។



## ២.៥.២. ដៃគូពាណិជ្ជកម្ម

| | | | |
|---|---|---|---|
| ភោជនីយដ្ឋាន សូគ៌ា | លីឡាស្ព័តក្លឹប | កាកាស៊ូគីស៊ុប | សាលាអន្តរជាតិ ហ្គ្រីនអែបផល |
| ពិសេស៖ 10% | ពិសេស៖ 5% | ពិសេស៖ 10% | ពិសេស៖ 30% |
| ស្តង់ដា៖ 10% | ស្តង់ដា៖ 5% | ស្តង់ដា៖ 10% | ស្តង់ដា៖ 30% |
| ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត |



| | | | |
|---|---|---|---|
| អ៊ីលីត ឡាហ្គារ | ធី ស៊ប | Modish | មន្ទីរពេទ្យទន្តសាស្ត្រនិង សម្ផស្សរំចង់ គ្រប់សាខា |
| ពិសេស៖ 20% | ពិសេស៖ 10% | ពិសេស៖ 10% | ពិសេស៖ 10% |
| ស្តង់ដា៖ 20% | ស្តង់ដា៖ 10% | ស្តង់ដា៖ 10% | ស្តង់ដា៖ 10% |
| ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត |

| | | | |
|---|---|---|---|
| Moon River | IORA | Heatwave | Blanca Laise Boutique Café |
| ពិសេស៖ 10% | ពិសេស៖ 10% | ពិសេស៖ 10% | ពិសេស៖ 5% |
| ស្តង់ដា៖ 10% | ស្តង់ដា៖ 10% | ស្តង់ដា៖ 10% | ស្តង់ដា៖ 5% |
| ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត |



| | | | |
|---|---|---|---|
| Home Star ម៉ាស្សា និងស្ប៉ា | ម្លប់ស្វាយ 99 សាច់អាំង ស៊ុគីស៊ុប | មណ្ឌលវេជ្ជសាស្ត្រ ស្ថានទូត | Spicy Sisters |
| ពិសេស៖ 20% | ពិសេស៖ 10% | ពិសេស៖ 3% | ពិសេស៖ 5% |
| ស្តង់ដា៖ 20% | ស្តង់ដា៖ 10% | ស្តង់ដា៖ 3% | ស្តង់ដា៖ 5% |
| ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត |

| | | | |
|---|---|---|---|
| គ្លីនិកឯកទេសជំងឺផ្លូវចិត្ត ពៅ ប៊ុនធឿន | សណ្ឋាគារ ហ្គូដ ឡាក់ ដេ | មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ប៊ីយ៉ូប៊ីឃិន | វិទ្យាស្ថាន អ៊ី អិល ធី គ្រប់សាខា |
| ពិសេស៖ 10% | ពិសេស៖ 10% | ពិសេស៖ 20% | ពិសេស៖ 20% |
| ស្តង់ដា៖ 15% | ស្តង់ដា៖ 10% | ស្តង់ដា៖ 15% | ស្តង់ដា៖ 20% |
| ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត | ភ្នំពេញ ព័ត៌មានលំអិត |

## ២.៦. ទស្សនៈវិស័យ បេសកកម្ម

### ២.៦.១. ទស្សនៈវិស័យ

ទស្សនៈវិស័យរយៈពេលវែងរបស់ អេ អឹម ខេ គឺដើម្បីសង្គមកម្ពុជាដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេហើយអាចជួយជាវិភាគទានយ៉ាងមានប្រយោជន៍ចំពោះការអភិវឌ្ឍប្រទេសជាតិ។

### ២.៦.២. បេសកកម្ម

បេសកកម្មជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុសមស្រប និងបិតថេរ។

### ២.៦.៣. វប្បធម៌រួម

វប្បធម៌រួមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គឺ កាយ វាចា និងការអភិវឌ្ឍន៍ដោយកំណត់ឡើងដោយគ្រឹះស្ថាន ហើយត្រូវបានបុគ្គលិកយល់ថាគួរតែគោរព និងអនុវត្តន៍តាមៈ

**ក.កាយ**

- ត្រូវរៀបចំខ្លួនឲ្យស្អាតបាត និងប្រកាន់ខ្ជាប់នូវឯកសណ្ឋាន
- ត្រូវរៀបចំកន្លែងធ្វើការឲ្យមានរបៀបរៀបរយ និងប្រកបដោយផាសុភាព
- ត្រូវញញឹម រួសរាយរាក់ទាក់ និងកាយវិការទន់ភ្លន់ជានិច្ច

**ខ.វាចា**

- ត្រូវនិយាយដោយសុភាពរាបសារ ទន់ភ្លន់ និង ថ្លៃថ្នូរ
- ត្រូវនិយាយនូវពាក្យពិត ត្រឹមត្រូវ និងច្បាស់លាស់
- ត្រូវនិយាយនូវអ្វីដែលមានប្រយោជន៍ល្អដល់គ្រឹះស្ថាន

**គ.ចិត្ត**

- ត្រូវមានភាពស្មោះត្រង់ ការប្តេជ្ញាចិត្តខ្លួន និងប្រកបដោយការទទួលខុសត្រូវ
- ត្រូវមានការគោរព និងអនុវត្តតាមគោនយោបាយរបស់គ្រឹះស្ថាន និងច្បាប់រដ្ឋ
- ត្រូវមានការស្រលាញ់រាប់អាន និងឲ្យតម្លៃគ្នាទៅវិញទៅមក

**ឃ.ការអភិវឌ្ឍន៍**

- ត្រូវបើកចិត្តទូលាយក្នុងការទទួលយកនូវការកែលម្អដើម្បីភាពប្រសើរឡើង
- ត្រូវអភិវឌ្ឍន៍ខ្លួនតាមរយៈការសិក្សារៀនសូត្រជាប្រចា

## ២.៧. រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា



## ២.៨. ផលិតផល និងសេវាកម្មទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

១.ប្រាក់កម្ចី

កម្ចីជាក្រុម

- កម្ចីសងដើមចុងវគ្គ - ធនាគារភូមិ
- កម្ចីសងរំលស់ - ធនាគារភូមិ
- កម្ចីសងបណ្តាក់ - ធនាគារភូមិ

កម្ចីឯកត្តជន

- កម្ចីពង្រីកអាជីវកម្ម
- កម្ចីកែលម្អគេហដ្ឋាន
- កម្ចីកសិកម្ម
- កម្ចីទូទៅ
- ភតិសន្យា (សេវាបង់រំលស់)
- កម្ចីអាជីវកម្មខ្នាតតូច និងមធ្យម
- កម្ចីសង្គ្រោះបន្ទាន់

ប្រាក់សន្សំ

- គណនីសន្សំងាយស្រួល
- គណនីសន្សំសំណាង
- គណនីមានកាលកំណត់
- គណនីអនាគត
- គណនីកូនឆ្លាត
- គណនីសោធនិវត្តន៍

សេវាផ្ទេរប្រាក់

- ធានារ៉ាប់រងខ្នាតតូច
- សេវាទូទាត់
- សេវាបើកប្រាក់បៀវត្សរ៍
- សេវាទូទាត់រហ័ស
- សេវាផ្ទេរប្រាក់ក្រៅប្រទេស

# ជំពូកទី៣

# ឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា

## ៣.១. ទីផ្សារគោលដៅសម្រាប់ឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យម

ផលិតផលនេះត្រូវបានយកចិត្តទុកដាក់ ជាពិសេសសម្រាប់បម្រើតម្រូវការទីផ្សារ ទៅតាមកម្រិតដែលអាចទទួលយកបានរបស់អតិថិជនគ្រប់រូបនៅកម្ពុជា នៅទីជនបទ ទីប្រជុំជន ទីក្រុង និងតំបន់នានាទៀតនៅក្នុងប្រទេសកម្ពុជា។ ទីផ្សារគោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺប្រជាជនកម្ពុជាគ្រប់រូប ដែលស្ថិតក្នុងសហគមន៍សេដ្ឋកិច្ចចាប់ពីកម្រិតទាបបំផុតឡើងទៅ លក្ខណៈជាគ្រួសារ ( ឯកត្តជន) ឬចងក្រងជាក្រុមដែលសកម្មភាពមុខរបរអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យរបស់មីក្រូហិរញ្ញវត្ថុ។

ក្រុមគោលដៅសម្រាប់ទីផ្សារឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ៖

- មុខរបរមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា ដែលមានស្ថានភាពល្អនៅក្នុងទីផ្សារហើយមុខរបរមានសក្តានុពល
- មានកេរ្តិ៍ឈ្មោះ និងទំនាក់ទំនងល្អ
- សកម្មភាពមុខរបរស្របច្បាប់
- លំហូរសាច់ប្រាក់មានស្ថេរភាព

## ៣.២ ឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យម

ឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យម គឺជាប្រភេទសេវាប្រាក់កម្ចី ដែលផ្តល់ជូនលក្ខណៈបុគ្គលទៅដល់ម្ចាស់សហគ្រាសខ្នាតតូច និងខ្នាតមធ្យម (សហគ្រាសជំនួញ ផលិតកម្មសេវាកម្ម និងកសិកម្ម) ដែលមានបំណងប្រើប្រាស់ឥណទាននេះសម្រាប់ធ្វើជាទុនវិនិយោគ ឬជាទុនបង្វិល ក្នុងការបង្កើតអាជីវកម្មថ្មី ឬពង្រីកអាជីវកម្មរបស់ខ្លួនដែលមានស្រាប់។

### ៣.២.១. ផលិតផលឥណទានខ្នាតតូច

#### ៣.២.១.១. ទំហំឥណទាន

**ឥណទានខ្នាតតូច សម្រាប់ឥណទានទោល**

- ប្រភេទរូបិយ ប័ណ្ណ ៖ ប្រាក់រៀល ប្រាក់ដុល្លារ និងប្រាក់បាតថៃ
- ទំហំកម្ចីប្រាក់រៀល ៖ រហូតដល់ ២.០០០.០០០រៀល

- ទំហំកម្ចីប្រាក់ដុល្លារ ៖ រហូតដល់ ៥០០ដុល្លារ
- ទំហំកម្ចីប្រាក់បាតថៃ ៖ រហូតដល់ ២០.០០០បាត
- រយៈពេលកម្ចី ៖ ចាប់ពី ៣ រហូតដល់ ១២ ខែ
- អត្រាការប្រាក់ប្រចាំខែ ៖ NA
- របៀបងសង ៖ បង់រំលោះទាំង ដើម និង ការប្រាក់
- អតិថិជនទាំងអស់នឹងទទួលបានអត្ថប្រយោជន៍បន្ថែម ដូចជា៖

-អាចខ្ចីកម្ចីសង្គ្រោះបន្ទាន់

-ទិញ ធានារ៉ាប់រងខ្នាតតូច លើ សុខ ភាព និង គ្រោះថ្នាក់

-លុបបំណុលក្នុងករណីទទួលមរណៈ ភាព ជាយ ថា ហេតុ

**ឥណទានខ្នាតតូច សម្រាប់ឥណទានក្រុម**

- ប្រភេទរូបិយ ប័ណ្ណ ៖ ប្រាក់រៀល និង ប្រាក់បាតថៃ
- ទំហំកម្ចី ៖ រហូតដល់ ៣.០០០.០០០ រៀល ឬទំហំទឹកប្រាក់ ដែល មាន តម្លៃស្មើ
- រយៈពេលកម្ចី ៖ ចាប់ពី ៣ ដល់ ១២ ខែ
- អត្រាការប្រាក់ប្រចាំខែ ៖ NA
- របៀបបង់សង ៖ បង់ ការប្រាក់ ប្រចាំខែ និង បង់ ប្រាក់ ដើម នៅ ចុង វគ្គ
- អតិថិជនកម្ចីទាំងអស់អាចទទួលបានអត្ថប្រយោជន៍បន្ថែម ដូចជា ៖

- អាចខ្ចីកម្ចីសង្គ្រោះបន្ទាន់

- ទិញ ធានារ៉ាប់រងខ្នាតតូចលើសុខភាព និង គ្រោះថ្នាក់

- លុបបំណុលចោលក្នុងករណីទទួលមរណភាព ជាយ ថា ហេតុ

### ៣.២.២. ផលិតផលឥណទានខ្នាតមធ្យម

#### ៣.២.២.១. ទំហំឥណទាន

ចំពោះឥណទានខ្នាតមធ្យម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ផ្តល់ជូនអតិថិជនតែជាប្រាក់ដុល្លារ។ អេ អឹម ខេ ផ្តល់ជូនចំពោះអតិថិជននូវទំហំឥណទានចាប់ពី ២,៥០០ដុល្លារ រហូតដល់ ២០,០០០ដុល្លារ។

#### ៣.២.២.២. ការកំណត់ថ្លៃ

**ក.អត្រាការប្រាក់**

- អត្រាការប្រាក់អបរមា១.៥% ក្នុងមួយខែលើសសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំពី ២,៥០០ដុល្លារ ដល់ ៥,០០០ដុល្លារ ។

**ខ.រយៈពេល**

ចំពោះរយៈពេល គ្រឹះស្ថានផ្តល់ជូនរយៈពេលអតិបរមា ៥ឆ្នាំ គ្រប់ទំហំឥណទាន។

## ៣.៣. ការកំណត់ទំហំឥណទាន និងថ្លៃសេវា

### ៣.៣.១. ការកំណត់ទំហំឥណទាន

ការកំណត់ទំហំឥណទានត្រូវផ្អែកទៅលើទ្រព្យធានា និង លទ្ធភាពសង។ ទ្រព្យធានាមានដូចជា ប្លង់ដី ផ្ទះ និង អាគារជាដើម ហើយលទ្ធភាពសងវិញ គឺពិនិត្យលើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនដែលផ្អែកលើ សកម្មភាពជំនួញ សមត្ថភាព ជំនាញ ភាពប៉ិនប្រសប់ ការទទួលខុសត្រូវ និងហានីភ័យដែលអាចជួបប្រទះ។

### ៣.៣.២. ថ្លៃសេវា

- អតិថិជនត្រូវបង់សេវាព័ត៌មាន នូវពេលដែលអតិថិជនត្រូវបានអនុម័តថាអាចទទួលបានឥណទាន។ សេវាខ្លះគិតទៅតាមទំហំឥណទាន និងអតិថិជនដូចខាងក្រោម៖

  - កម្ចីចាប់ពី ៥,០០០ដុល្លារ ដល់ ៥០,០០០ដុល្លារ

- ក្នុងករណីដែលអតិថិជនសម្រេចយកអត្រាការប្រាក់ទាបជាងអត្រាកំណត់អតិថិជនត្រូវបង់ថ្លៃសេវាប្រតិបត្តិការ ១% លើទំហំឥណទានសរុប។

## ៣.៤. ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម

### ៣.៤.១. ការវាយតម្លៃក្នុងការផ្តល់ឥណទាន

មុននឹងសម្រេចផ្តល់ឥណទានដល់អតិថិជន មន្ត្រីឥណទានត្រូវធ្វើការវាយតម្លៃទៅលើ៖

#### ៣.៤.១.១. អត្តចរិតរបស់អតិថិជន

អត្តចរិតរបស់អតិថិជន គឺសំដៅទៅលើថាតើអ្នកស្នើសុំខ្ចីជាអតិថិជនប្រភេទណា?ជាប្រភេទខ្ចីស្រួលសងពិបាក ឬក៏អត់ដោយមើលទៅលើអាកប្បកិរិយា ការគិត សកម្មភាព ភាពស្មោះត្រង់ និងការទទួលខុសត្រូវរបស់អតិថិជនព្រោះវាជាកត្តាដ៏សំខាន់ក្នុងការធ្វើឲ្យមានគុណភាពនៃប្រាក់កម្ចី។

#### ៣.៤.១.២. ដើមទុន

ដើមទុន សំដៅទៅលើដើមទុនផ្ទាល់ខ្លួនរបស់អតិថិជន ក្នុងការចូលរួមគម្រោងវិនិយោគ។ ជាទូទៅគ្រឹះស្ថានតែងតម្រូវឲ្យអតិថិជនត្រូវមានសាច់ប្រាក់ផ្ទាល់ខ្លួន ដើម្បីចូលរួមក្នុងគម្រោងវិនិ

យោគយ៉ាងហោចណាស់ ៣០% នៃទុនវិនិយោគទាំងអស់។

**៣.៤.១.៣. សមត្ថភាពសង**

សមត្ថភាពសង វាយតម្លៃលំហូរសាច់ប្រាក់របស់អតិថិជន ប្រាក់ចំណូលពី មុខរបរនិង ប្រភពចំណូលផ្សេងៗ ដើម្បីធ្វើការប៉ាន់ស្មានតម្រូវការឥណទានរយៈពេលឥណទាន និងលទ្ធភាពសងប្រាក់។

**៣.៤.១.៤. ទ្រព្យធានា**

ទ្រព្យធានា បានបែងចែកជាបីមានដូចជា ៖ កាត់គ្រីម៉ូតូ កាត់គ្រីឡាន ប្លង់រឹង និង ប្លង់ទុនល..។

**៣.៤.១.៥. លក្ខខណ្ឌ**

លក្ខខណ្ឌ ជាកត្តាផ្សេងៗដែលអាចជៈឥទ្ធិពលដល់អាជីវកម្ម ចរិក លទ្ធភាពសងរបស់អតិថិជនជាដើម។

**៣.៤.២. នីតិវិធីក្នុងការផ្តល់ឥណទាន**

នីតិវិធីក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា មានដូចខាងក្រោមៈ

**៣.៤.២.១. ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់**

ជាដំបូង អ្នកដាក់ពាក្យសុំខ្ចីប្រាក់ត្រូវមកជួបភ្នាក់ងារបម្រើអតិថិជន (Customer Service) នៅតាមសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដើម្បីឲ្យភ្នាក់ងារបម្រើអតិថិជន ធ្វើការពន្យល់ពីគោលការណ៍ នីតិវិធីឥណទាន និងលក្ខខណ្ឌរួមស្តីពីការខ្ចីប្រាក់ឲ្យបានច្បាស់លាស់ ទៅអ្នកចុះឈ្មោះសុំខ្ចីប្រាក់រួមមាន ទំហំរបស់ឥណទាន របៀបសង អត្រាការប្រាក់ អ្នកធានា រួចផ្តល់ពាក្យសុំខ្ចី និងជម្រាបជូនអតិថិជនស្តីពីលិខិតស្នាមចាំបាច់ដែលជាតម្រូវការរបស់គ្រឹះស្ថាន។

ក្រោយពីទទួលពាក្យសុំខ្ចីប្រាក់ ដែលបានបំពេញបានត្រឹមត្រូវដោយអតិថិជន ភ្នាក់ងារបម្រើអតិថិជនត្រូវប្រមូលឯកសារ ដែលបាននោះដាក់ក្នុងប្រអប់ឯកសាររបស់ភ្នាក់ងារឥណទានទទួលខុសត្រូវ។ គួរកត់សំគាល់ផងដែលថា អ្នកស្នើសុំខ្ចីប្រាក់អាចទំនាក់ទំនងដាក់ពាក្យជាមួយភ្នាក់ងារឥណទានក្នុងពេលដែល ភ្នាក់ងារឥណទានចុះធ្វើការនៅតាមមូលដ្ឋាន។

**៣.៤.២.២. ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន**

ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន ធ្វើឡើងក្រោយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានពាក្យសុំ ចុះឈ្មោះខ្ចីប្រាក់របស់អតិថិជន។ ភ្នាក់ងារឥណទានត្រូវចុះទៅជួបអតិថិជនដល់ទីលំនៅ និងអ្នករួមកម្ចី ដើម្បីសាកសួរព័ត៌មានតម្រូវការខ្ចីប្រាក់។ នៅពេលសាកសួរ ភ្នាក់ងារឥណទានរបស់

គ្រឹះស្ថាន ត្រូវយកចិត្តទុកដាក់ផ្តោតអារម្មណ៍ក្នុងការសាកសួរប្រមូលព័ត៌មានពីអ្នកខ្ចី ដែលទាក់ទងនឹងព័ត៌មានទូទៅ ព័ត៌មានហិរញ្ញវត្ថុ គោលបំណង និងតម្រូវការនៃការប្រើប្រាស់ប្រាក់កម្ចី កិច្ចសន្យាដាក់ធានា សាកសួរអំពីកត្តាទាំងឡាយ ដែលអាចជះឥទ្ធិពលបង្កហានិភ័យ។ ភ្នាក់ងារឥណទានក៏ត្រូវពន្យល់ឲ្យបានច្បាស់លាស់ពីគោលការណ៍ និង នីតិវិធីឥណទាន ដោយរាប់បញ្ចូលទាំងកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាធានា ឬកិច្ចសន្យាព្រមព្រៀងធានា។

ភ្នាក់ងារឥណទានត្រូវធ្វើការត្រិះរិះពិចារណា សិក្សាវិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានទាំងនោះ ថាតើពិតជាត្រឹមត្រូវ សម្រាប់ធ្វើការវាយតម្លៃឥណទានហើយឬនៅ? ករណីដែលអតិថិជនផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ភ្នាក់ងារឥណទាន អាចចុះស្រាវជ្រាវប្រមូលព័ត៌មានបន្ថែមពីខាងក្រៅ ឬពីអាជ្ញាធរមូលដ្ឋានផងដែរ ប៉ុន្តែត្រូវរក្សាអាថ៌កំបាំងវិជ្ជាជីវៈ ជៀសវាងការបង្កឲ្យកើតមានផលមិនល្អ។ ក្រោយពីធ្វើការវាយតម្លៃលទ្ធភាពរបស់អ្នកខ្ចីប្រាក់រួច ភ្នាក់ងារឥណទានត្រូវតែបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាព ដែលអាចទទួលឥណទានបាន លក្ខខណ្ឌឥណទាននិងបណ្តុះវិន័យឥណទាន។

### ៣.៤.២.៣. ការរៀបចំឯកសារខ្ចីប្រាក់

ការរៀបចំឯកសារខ្ចីប្រាក់អាចប្រើប្រាស់និងអាចប្រព្រឹត្តទៅបានបន្ទាប់ពីមានការព្រមព្រៀងពីអតិថិជន។ ភ្នាក់ងារឥណទានត្រូវរៀបចំឯកសារសម្រាប់ អតិថិជនខ្ចីប្រាក់ក្នុងនោះរួមមាន ទម្រង់សម្ភាសន៍កំណត់ហេតុវាយតម្លៃទ្រព្យសម្បត្តិដាក់ធានា គម្រោងជំនួញ និងឲ្យអតិថិជនដាក់ពាក្យសុំខ្ចីប្រាក់។ ភ្នាក់ងារឥណទានអាចសរសេរយោបល់ និងសំណើរបស់ខ្លួនដើម្បីស្នើសុំការអនុម័តប្រសិនបើអ្នកខ្ចី អ្នករួមខ្ចី ឬអ្នកធានាយល់ព្រមដាក់ទ្រព្យធានារបស់ពួកគេធានាប្រាក់កម្ចី ដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងគម្រោងជំនួញ។

### ៣.៤.២.៤. ការអនុមត័ឥណទាន

ឥណទានដែលបានអនុម័តត្រូវតែមានយោបល់ និងសំណើពីភ្នាក់ងារឥណទានទទួលខុសត្រូវមានសេចក្តីសុខបញ្ជាក់ពីប្រធានការិយាល័យស្រុក ខណ្ឌ ឬភ្នាក់ងារឥណទាន និងពីនាយក នាយិកា គ្រឹះស្ថានលើពាក្យសុំខ្ចីប្រាក់រួមជាមួយគម្រោងជំនួញ និងឯកសារសម្គាល់របស់អតិថិជនខ្លះទៀតផ្ញើទៅនាយកដ្ឋានឥណទាន។ ក្រោយពីត្រួតពិនិត្យហើយ នាយកដ្ឋានឥណទានដាក់សំណើសុំឥណទានជូននាយកប្រតិបត្តិឥណទានដើម្បីពិនិត្យ និងបញ្ជូនទៅគណៈកម្មាធិការឥណទាន។

### ៣.៤.២.៥. ការរៀបចំកិច្ចសន្យា

ភ្នាក់ងារឥណទាន ត្រូវទៅជួបអ្នកដាក់ពាក្យខ្ចីដល់ផ្ទះម្តងទៀត បន្ទាប់ពីឥណទានបានអនុម័ត

ហើយដើម្បីរៀបចំកិច្ចសន្យាក្នុងនោះមាន កិច្ចសន្យាបរិភោគ កិច្ចសន្យាដាក់ទ្រព្យធានា និងលិខិតផ្សេងៗទៀតដែលទាក់ទង។ ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវលើការរៀបចំឯកសារទាំងអស់។ បន្ទាប់ពីមានការព្រមព្រៀងហើយអតិថិជន និងអ្នកដែលទាក់ទងទាំងអស់ត្រូវផ្តិតមេដៃ ឬចុះហត្ថលេខានៅចំពោះមុខភ្នាក់ងារឥណទាន។ ចំពោះឯកសារណាដែលត្រូវបញ្ជាក់ពីអាជ្ញាធរ អតិថិជនត្រូវរត់ការសុំបញ្ជាក់ ចុះហត្ថលេខា និងបោះត្រាពីអាជ្ញាធរដោយខ្លួនឯង។ ក្រោយពីឯកសារទាំងអស់នោះបានបំពេញត្រឹមត្រូវគ្រប់គ្រាន់ និងបានចុះហត្ថលេខាបញ្ជាក់ចប់សព្វគ្រប់រួចរាល់ហើយ ភ្នាក់ងារឥណទានត្រូវយកឯកសារទាំងនោះមកការិយាល័យហើយប្រគល់ទៅឲ្យប្រធានភ្នាក់ងារឥណទាន។

**៣.៤.២.៦. ការបញ្ចេញឥណទាន**

គ្រប់ឯកសារទាំងអស់ដែលទាក់ទងនឹងការបញ្ចេញឥណទាន ត្រូវតែរៀបចំឲ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវសិនមុនពេលដែលបញ្ចេញឥណទាន រួចត្រូវបញ្ជូនទៅឲ្យបេឡាធិការរៀបចំប្រាក់ហើយរង់ចាំអតិថិជនមកបើកប្រាក់។ អតិថិជនត្រូវមកជួបបេឡាធិការដើម្បីបើកប្រាក់។ មុនពេលបើកប្រាក់បេឡាធិការត្រូវរំលឹកអតិថិជនឡើងវិញ អំពីគោលការណ៍សំខាន់ៗដូចជា របៀបសងប្រាក់ និងការពិន័យលើការសងយឺតយ៉ាវ និងប្រាក់អតិថិជនពីច្បាប់នៃការគ្រប់គ្រងទទួលប្រាក់ដូចជា អតិថិជនត្រូវ
តែពិនិត្យ និងរាប់ប្រាក់ឲ្យបានត្រឹមត្រូវមុនពេលចាកចេញ។ អតិថិជនត្រូវផ្តិតមេដៃលើលិខិតដកប្រាក់ទើបអាចទទួលប្រាក់បាន។

**៣.៤.៣. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន**

ដើម្បីអាចដាក់ពាក្យស្នើសុំឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ បានអតិថិជនត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានទីលំនៅពិតប្រាកដនៅកន្លែងដែល អេ អឹម ខេ ធ្វើប្រតិបត្តិការ
- មានអាយុចាប់ពី ១៨ ដល់ ៦២ ឆ្នាំ
- មានសុខភាពល្អ
- មានទ្រព្យធានា
- មានអាជីវកម្ម ឬមុខរបរច្បាស់លាស់
- អ្នករួមខ្ចី
- មានសាក្សី

- មានអ្នកធានា
- មានឯកសារផ្លូវការ
- ស្ថានភាពគ្រួសារល្អ
- មិនស្ថិតនៅក្នុងបញ្ជីបដិសេធ

### ៣.៤.៤. ការសងត្រលប់មកវិញនៃឥណទាន

#### ៣.៤.៤.១. ការគណនាការប្រាក់

ក. រូបមន្តគ្រឹះសម្រាប់គណនាការប្រាក់សាមញ្ញគឺ

*** ការប្រាក់ I = P * r * t**

P - ប្រាក់ដើម

r - អត្រាការប្រាក់គិតក្នុងមួយគ្រា t - រយៈពេល(ចំនួនថ្ងៃ)

**ឧទាហរណ៍៖** លោក M បានខ្ចីប្រាក់ពីគ្រឹះស្ថានចំនួន ១,០០០,០០០ រៀល សម្រាប់រយៈពេល ១ឆ្នាំ ដោយគិតអត្រាការប្រាក់ ២.៥% ក្នុងមួយខែ។ តើលោកត្រូវបង់ការប្រាក់សរុបប៉ុន្មាន?

**ដំណោះស្រាយ**

រូបមន្ត I = P x r x t

នាំឲ្យ = ១,០០០,០០០ x ២.៥% x ១២

= ២៨៨០០០, រៀល

#### ៣.៤.៤.២. របៀបសងប្រាក់

ការសងត្រឡប់មកវិញនៃឥណទានត្រូវបានអនុវត្តទៅតាមតារាងកាលវិភាគសងប្រាក់ដែលបានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់។ អេ អឹម ខេ ផ្តល់ជូនអតិថិជនរបស់ខ្លួននូវជម្រើស ៣ ក្នុងការសងប្រាក់ដែលមានដូចជា៖

**ក. ប្រាក់ត្រូវបង់មានបរិមាណថេររៀងរាល់ខែហៅបានម្យ៉ាងទៀតថាធនលាភ(Annuity)**

<u>ឧទាហរណ៍</u>៖ ប្រាក់ កម្ចី=50.000.000៛ អត្រាការប្រាក់ (APR)=12% រំលោះ រយៈពេល 2 ឆ្នាំ បង់ ប្រចាំខែ ។

ប្រាក់ ត្រូវបង់ប្រចាំខែថេរ (ធនលាភ)

ក្នុង វិធី នេះ ប្រាក់រំលោះ មាន បរិមាណ ថេរ ។ ធនលាភ អ្នកអាច គណនា តាម រយៈ រូបមន្ត ដូចខាងក្រោម ៖

$$A = \frac{D \times i}{1-(1+i)^{-n}}$$

ដែល A: ទឹក ប្រាក់ ត្រូវ ទូទាត់ ប្រចាំខែ (ធនលាភ)

D: ប្រាក់ដើមសរុប

i: អត្រាការប្រាក់ ប្រចាំខែ

n: ចំនួន ខែ សរុប

ក្នុង ឧទាហរណ៍ នេះ D=50.000.000៛

i=12%/12=1% ក្នុង មួយ ខែ

n=2ឆ្នាំ x 12ខែ = 24 ខែ

$$A = \frac{50.000.000៛ \times 0.01}{1-(1+0.01)^{-24}} = 2.353.674៛$$

នោះ

ពេល រក ធនលាភ បាន ហើយ អ្នក ត្រូវ បង្កើត តារាង រំលោះដូចខាងក្រោម៖

| ខែ | ប្រាក់ត្រូវបង់ប្រចាំខែ | រំលោះប្រាក់ដើម | ការប្រាក់ | សមតុល្យប្រាក់ដើម |
|---|---|---|---|---|
| 0 | - | - | - | 50.000.000 |
| 1 | 2.353.674 | 1.853.674 | 500.000 | 48.146.326 |
| 2 | 2.353.674 | 1.872.211 | 481.463 | 46.274.115 |
| 3 | 2.353.674 | 1.890.933 | 462.741 | 44.383.182 |
| 4 | 2.353.674 | 1.909.842 | 443.832 | 42.473.340 |
| 5 | 2.353.674 | 1.928.941 | 424.733 | 40.544.400 |
| 21 | 2.353.674 | 2.261.835 | 91.839 | 6.922.110 |
| 22 | 2.353.674 | 2.284.453 | 69.221 | 4.637.657 |
| 23 | 2.353.674 | 2.307.297 | 46.377 | 2.330.360 |
| 24 | 2.353.674 | 2.330.370 | 23.304 | - |

ប្រាក់ត្រូវបង់ប្រចាំខែថេរ (ធនលាភ) ក្នុង តារាង នេះ អ្នក ត្រូវ ចាប់ផ្តើម មើល ពី ជួរ សមតុល្យ ប្រាក់ដើម ។ នៅ ពេល ការបង់រំលោះ ចាប់ផ្តើម គឺ ខែទីសូន្យ សមតុល្យ ប្រាក់ដើម គឺ 50.000.000៛ ។ បន្ទាប់ អ្នក ត្រូវ បំពេញ ធនលាភ ចូល ក្នុង ជួរប្រាក់ ត្រូវ បង់ ប្រចាំខែ ចាប់ពី ខែ ទី មួយ ។ នេះ ជា ប្រាក់ ដែល អ្នក ត្រូវ បង់ ប្រចាំខែ ដែល រួមមាន រំលោះ ប្រាក់ដើម និង ការប្រាក់ ។ ការប្រាក់ ស្មើរ នឹង សមតុល្យ ប្រាក់ដើម គុណនឹង អត្រា ការប្រាក់ ប្រចាំ ខែ អាច គណនា បាន យ៉ាង ស្រួល

តែ ប្រែប្រួល រៀងរាល់ខែ តាម សមតុល្យ ប្រាក់ដើម ។ រំលោះ ប្រាក់ដើម អាច គណនា បាន ដោយ យក ប្រាក់ត្រូវ បង់ ប្រចាំខែ ដក ការប្រាក់ដែល បាន រក ឃើញ ចេញ ។ ឯ សមតុល្យ ប្រាក់ដើម គឺស្មើរ នឹង ប្រាក់ដើម ពី ខែ មុន ដក នឹង រំលោះ ប្រាក់ដើម ។ អ្នក ធ្វើ បែប នេះ រហូត ដល់ ខែ ទី ២៤ ដែល សមតុល្យ ប្រាក់ដើម ស្មើរ សូន្យ ជា ការបញ្ចប់ សំណាង បំណុល ។

**ខ. ប្រាក់ រំលោះ លើ ប្រាក់ដើម ថេរ រៀង រាល់ ខែ**

**ប្រាក់រំលោះលើ ប្រាក់ដើម ថេរ និងការប្រាក់**

| ខែ | ប្រាក់ត្រូវបង់ប្រចាំខែ | រំលោះប្រាក់ដើម | ការប្រាក់ | សមតុល្យប្រាក់ដើម |
|---|---|---|---|---|
| 0 | - | - | - | 50.000.000 |
| 1 | 2.583.334 | 2.083.334 | 500.000 | 47.916.666 |
| 2 | 2.562.501 | 2.083.334 | 479.167 | 45.833.332 |
| 3 | 2.541.667 | 2.083.334 | 458.333 | 43.749.998 |
| 4 | 2.520.834 | 2.083.334 | 437.500 | 41.666.664 |
| 5 | 2.500.001 | 2.083.334 | 416.667 | 39.583.330 |
| 21 | 2.166.667 | 2.083.334 | 83.333 | 6.249.986 |
| 22 | 2.145.834 | 2.083.334 | 62.500 | 4.166.652 |
| 23 | 2.125.001 | 2.083.334 | 41.667 | 2.083.318 |
| 24 | 2.104.151 | 2.083.318 | 20.833 | - |

រំលោះលើប្រាក់ដើមថេរ

វិធីនេះខុសពីវិធីមុនត្រង់ប្រាក់រំលោះប្រាក់ដើមថេរតែប្រាក់ត្រូវបង់ប្រចាំខែមិនថេរឡើយ ។ ប្រាក់រំលោះ ប្រាក់ដើមស្មើរ នឹងប្រាក់ដើមចែក នឹងចំនួនខែសរុបឯប្រាក់ត្រូវទូទាត់ប្រចាំខែស្មើរ នឹងប្រាក់រំលោះនេះ បូក នឹងការប្រាក់ ។ ចំណែកយន្តការនៃតារាងរំលោះមានភាពដូចគ្នា នឹងតារាងមុនដែរ ។

រំលោះប្រាក់ដើម = 50.000.000៛/24ខែ = 2.083.334៛ ។

**គ. ប្រាក់រំលោះថេរក្នុងបរិមាណទាបសម្រាប់រយៈពេលកំណត់មួយដោយទុកប្រាក់ដើមភាគធំដែលនៅសល់សម្រាប់បង់ផ្តាច់នៅចុងកាលឥណប្រទាន(ប្រាក់ បាឡុង ឬ Balloon Payment)**

ក្នុងចំណោមវិធីទាំងនេះវិធីចុងក្រោយគេមិនទទួលបានការពេញនិយមនៅលើពិភពលោកទេក្រៅពីនៅស.រ.អាហើយការកំណត់ប្រាក់ត្រូវបង់ក៏ប្រែប្រួលយ៉ាងខ្លាំងទៅតាមម្ចាស់កម្ចី ។

### ៣.៤.៤.៣. ការសងត្រលប់មកវិញនៃឥណទាន

ភ្នាក់ងារឥណទានត្រូវធ្វើការវិភាគ និងវាយតម្លៃលទ្ធភាពសងរបស់អតិថិជនដើម្បីឲ្យប្រាកដថា ឥណទានត្រូវបានសងត្រឡប់មកវិញទាំងដើមទាំងការបានទាន់ពេលវេលា។ ការវាយតម្លៃប៉ាន់ស្មានលទ្ធភាពសងបំណុល ផ្អែកសំខាន់បំផុតលើចំណូលបច្ចុប្បន្នរបស់អ្នកខ្ចីជាមូលដ្ឋាន គឺមិនផ្អែកទៅលើចំណូលដែលនឹងកើតមាន ឬប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលនឹងទទួលបាននៅពេលអនាគតទេ។ ប្រសិនបើចំណូលសំខាន់ៗពីមុខរបរមិនគ្រប់គ្រាន់សម្រាប់សងបំណុលទេនោះ អាច

វិភាគលើចំណូលផ្សេងៗតែត្រូវធ្វើការសិក្សាឲ្យបានលម្អិតធ្វើយ៉ាងណាបង្ហាញឲ្យឃើញថា អ្នកខ្ចីពិតជាមានលទ្ធភាពអាចសងបំណុលបានទាំងស្រុង។

ករណីអតិថិជនសងបំណុលបញ្ចប់មុនកាលបរិច្ឆេទនៃកិច្ចសន្យាខ្ចីប្រាក់ ការប្រាក់ត្រូវកាត់បន្ថយត្រូវបានគណនាសមាមាត្រទៅនឹងចំនួនថ្ងៃដែលសងដាច់មុនកាលកំណត់នោះ។

**៣.៤.៤.៤. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ**

ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ អាចអនុញ្ញាតឲ្យបានចំពោះអតិថិជនដែលសងបំណុលប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់តែប៉ុណ្ណោះ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែលប៉ុន្តែកាត់បន្ថយចំនួនទឹកប្រាក់ដែលត្រូវសង។

**៣.៤.៤.៥. ការផ្តល់ឥណទានបន្ថែម**

ការផ្តល់ឥណទានបន្ថែមលើសមតុល្យឥណទានចាស់ត្រូវបានអនុញ្ញាតដោយអនុលោមទៅតាមនីតិវិធី និងសិទ្ធិក្នុងការអនុម័តឥណទានលុះត្រាតែះ

- អតិថិជនមានមុខរបររីកចម្រើន ចំណូលកើនឡើង ឬផ្តល់ឥណទានលើកមុនមិនទាន់អស់លទ្ធភាពហើយមុខរបរមានសក្តានុពល។
- អតិថិជនត្រូវការដើមទុនពង្រីកមុខរបរបន្ថែម និង មានទ្រព្យសម្បត្តិជានាគ្រប់គ្រាន់។

**៣.៤.៥. ការខកខានសង និងការពិន័យ**

**៣.៤.៥.១. ការខកខានសង**

ឥណទានមួយត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យា កាលណាដល់ពេលវេលាសងហើយអ្នកខ្ចីមិនបានសងទាន់ពេលវេលាដូចបានចែងក្នុងកិច្ចសន្យា និងតារាកាលវិភាគសងប្រាក់។ រយៈពេលខកខានសងប្រាក់ គឺជាចំនួនថ្ងៃដែលខកខានមិនបានសងតាមតារាងកិច្ចសន្យារាប់ចាប់ពីថ្ងៃយឺតដំបូង ហើយរយៈពេលនេះនឹងត្រូវកាត់បន្ថយក្នុងករណីទំហំទឹកប្រាក់បានសងសមាមាត្រទៅនឹងទំហំទឹកប្រាក់នៃចន្លោះរយៈពេលយឺតយ៉ាវសងនោះ។

- ❖ ចំពោះការខកខានសងចែកចេញជា ២ គឺ ៖
  - ការខកខានសងកម្រិតស្រាល គឺជាការខកខានសងប្រាក់ ឫទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលតិចជាង ៣០ ថ្ងៃ។
  - ការខកខានសងកម្រិតធ្ងន់ គឺជាការខកខានសងប្រាក់ ឫទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលចាប់ពី ៣០ ថ្ងៃ។

**៣.៤.៥.២. ការពិន័យ**

រូបមន្ត ៖ ប្រាក់ពិន័យ = ប្រាក់ដើមសងយឺត x ១% /៣០ x ចំនួនថ្ងៃដែលបានសងយឺត

**៣.៤.៦. ការធ្វើចំណាតថ្នាក់ឥណទាន និងសំវិធានធន**

សំវិធានធននៃឥណទានគឺត្រូវធ្វើឡើងដើម្បីបង្ការភាពបាត់បង់ ឬគ្រោះថ្នាក់ដោយយថាហេតុនៃចំនួនប្រាក់នៃឥណទានដែលខកខានមិនបានសងរបស់អតិថិជន។ សំវិធានធននៃឥណទានគឺត្រូវកំណត់ជាចំណាត់ថ្នាក់ដូចខាងក្រោម៖

**១. ការធ្វើវិធានធនលើបំណុលស្តង់ដា:(Standard Loan Provision)**

បំណុលស្តាង់ដារ គឺជាបំណុលដែលមានកាលកំណត់ត្រូវសងបំណាច់វគ្គ ឬប្រាក់ដើមសងក្នុងវគ្គដោយការសងមិនត្រូវបានខនខានលើសពីរយៈពេល៣០ថ្ងៃ។

**២. ការធ្វើសំវិធានធនលើបំណុលសង្ស័យ និងបំណុលអាក្រក់:**

**ក. បំណុលក្រោមស្តង់ដា ៖ (Substandard Loan Provision)**

បំណុលក្រោមស្តង់ដា គឺជាបំណុលដែលមានកាលកំណត់ត្រូវសងបំណាច់វគ្គ ឬប្រាក់ដើមក្នុងវគ្គដែលហួសរយៈពេលពី៣១ថ្ងៃដល់រយៈពេល៩០ថ្ងៃ។ ការធ្វើសំវិធានធនគឺត្រូវបានកំណត់ ១០% លើប្រាក់ដើមចំពាក់នៃបំណុលក្រោមស្តង់ដាជាក់ស្តែង។

**ខ.បំណុលសង្ស័យ ៖ (Doubtful Loan Provision)**

បំណុលសង្ស័យ គឺជាបំណុលដែលមានកាលកំណត់ត្រូវសងបំណាច់វគ្គ ឬប្រាក់ដើមក្នុងវគ្គដែលហួសរយៈពេល៩១ថ្ងៃ ដល់រយៈពេល៣៦០ថ្ងៃ។ ការធ្វើសំវិធានធន គឺត្រូវបានកំណត់ ៣០% លើប្រាក់ដើមជំពាក់បំណុលក្រោមស្តង់ដាជាក់ស្តែង។

**គ.បំណុលបាត់បង់ ៖ (Loan Loss Provision)**

បំណុលបាត់បង់ គឺជាបំណុលដែលមានកាលកំណត់ត្រូវសងបំណាច់វគ្គ ឬប្រាក់ដើមក្នុងវគ្គដែលហួសរយៈពេលលើសពី ៣៦០ថ្ងៃ ឡើងទៅ។ ការធ្វើសំវិធានធន គឺត្រូវបានកំណត់ ១០០% លើប្រាក់ដើមជំពាក់នៃបំណុលក្រោមស្តង់ដាជាក់ស្តែង។

**៣.៤.៧. ហានិភ័យឥណទាន**

**៣.៤.៧.១. និយមន័យហានិភ័យឥណទាន**

ហានីភ័យឥណទាន ជាហានីភ័យដ៏សំខាន់ ដែលអតិថិជន ឬ ដៃគូអាជីវកម្ម របស់ អេ អឹម ខេ មិនអាចអនុវត្តកាតព្វកិច្ច ដែលបានព្រមព្រៀងក្នុងកិច្ចសន្យា ។

**៣.៤.៧.២. មូលហេតុនៃហានិភ័យឥណទាន**

ហានិភ័យឥណទាន គឺជាហេតុការណ៍ដែលកើតឡើងដោយយថាហេតុដែលយើងមិនអាច

ស្ថានដល់។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញឲ្យឃើញថាហានីភ័យឥណទានអាចកើតឡើងអាស្រ័យដោយកត្តា ៣ យ៉ាងៈ

**ក. កត្តាអតិថិជន**

- ការយល់ពីលក្ខខណ្ឌឥណទានខុស មិនបានដឹង ពីគម្រោងនៃការសង បំណុលបាត់វិក្កយបត្រ ឫ វិក្កយបត្រផ្ញើមិនបានដល់។
- អ្នកខ្ចីមានគំនិតផ្តេកផ្តួលមិនចង់សងបំណុលបានបង្កើតនូវរប្បធម៌មើលបំណាំគ្នាកេងប្រវ័ញ្ចពេលវេលាសងការប្រាក់។ មិនគោរពតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀង និង ព្យាយាមបង្កើតបញ្ហាដើម្បីពន្យាពេលនៃការសង។
- អ្នករួមខ្ចីមានគំនិតរួមគ្នាជាក្រុម ឬជាមួយអ្នកជានាក្នុងការចែកឥណទាន បន្លំឯកសារដើម្បីទទួលបានឥណទានក្នុងគោលបំណងយកទៅប្រើប្រាស់ ខុសពីទិសដៅជំនួញដោយសារខ្លួនកំពុងជួបវិបត្តិហិរញ្ញវត្ថុជាមួយម្ចាស់បំណុលផ្សេងៗ។
- អតិថិជនមានប្រវត្តិរស់នៅមិនចុះសម្រុងជាមួយសង្គម ប្រព្រឹត្តល្បែងស៊ីសង អំពើអបាយមុខដែលបណ្តាលឲ្យអន្តរាយទ្រព្យសម្បត្តិ។
- ក្រុមគ្រួសារមានវិបត្តិ និងមានបំណងគេចវេស។ អតិថិជនមានឆន្ទៈក្នុងការសង ប៉ុន្តែដោយសារបញ្ហាកើតឡើងដូចជា សមាជិកគ្រួសារមានជំងឺ មុខរបរមានបញ្ហាដែលជាមូលហេតុនាំឲ្យអតិថិជនបាត់បង់លទ្ធភាពក្នុងការសងបំណុល។
- អាចត្រូវដៃគូ ឬអ្នកវិនិយោគដទៃទៀតបោកប្រាស់។ នៅពេលខ្លះដោយសារវិនិយោគគិន ឫសហគ្រិនទុកចិត្តទៅលើដៃគូវិនិយោគខ្លាំងពេក ធ្វើឲ្យពួកគេប្រឈមមុខនឹងការខាតបង់ដោយសារតែដៃគូវិនិយោគបោកប្រាស់ និងកេងផលចំណេញនៅក្នុងមុខរបរ។
- ការប្រើប្រាស់ប្រាក់ខុសគោលដៅ ៖ អតិថិជនមួយចំនួនប្រើប្រាស់ឥណទានដែលបានផ្តល់ឲ្យខុសគោលដៅ ដោយមិនបានយកឥណទានទាំងនោះទៅប្រើប្រាស់ទៅតាមគោលបំណងដែលខ្ចីទេ តែបែរជាយកប្រាក់កម្ចីទាំងនោះទៅប្រព្រឹត្តល្បែង ឬអំពើខុសច្បាប់ផ្សេងៗ។
- មុខរបរចម្បងដួលរលំ ឬមានបញ្ហាធ្ងន់ធ្ងរ (គ្មានចំណូល ឬក្ស័យធន) មុខរបរបន្ទាប់បន្សំមិនអាចទ្រទ្រង់ចំណាយបាន ដែលបណ្តាលឲ្យប៉ះពាល់ដល់ការសងត្រឡប់។
- អតិថិជនមានទំនាស់ក្នុងគ្រួសារធ្ងន់ធ្ងរ មានការបែកបាក់គ្នា ហើយម្នាក់ៗមិនទទួលខុសត្រូវលើបំណុលដែលកំពុងជំពាក់។
- ប្តី ឬប្រពន្ធ ឬអ្នករួមខ្ចី បាត់បង់ជីវិតដោយសារជំងឺ ឬដោយសារគ្រោះថ្នាក់ផ្សេងៗ -ល- ។

**ខ. កត្តាគ្រឹះស្ថានផ្ទាល់**

- កើតឡើងដោយអ្នកឲ្យខ្ចី និងបុគ្គលិកដែលពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ទៅលើការងាររបស់ខ្លួន ដូចជាភ្នាក់ងារឥណទានវាយតម្លៃប្រាក់កម្ចីមិនបានត្រឹមត្រូវ និងសិក្សាមិនបានល្អិតល្អន់ពីប្រវត្តិ និងអត្តចរិតអ្នកខ្ចី លំហូរសាច់ប្រាក់ លទ្ធភាពសង និងហានិភ័យដែលពាក់ព័ន្ធផ្សេងៗ។

- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់បំពេញឯកសារឥណទាន ឲ្យបានត្រឹមត្រូវ ឬមិនបានបង្កើតជាកិច្ចព្រមព្រៀងនានា ដើម្បីជំនួញ និងភស្តុតាងក្នុងការដោះស្រាយបំណុលអាច នឹងកើតមានឡើង។

- ភ្នាក់ងារធ្វើរបាយការណ៍ ដែលមិនឆ្លុះបញ្ចាំង ពីស្ថានភាពជាក់ស្តែងរបស់ អតិថិជន

- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន និងត្រួតពិនិត្យបំណុលឲ្យទាន់ពេលវេលា។

**គ. កត្តាសង្គម និងធម្មជាតិ**

- សង្គម ៖ សង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល នយោបាយសេដ្ឋកិច្ច

- វិបត្តិសេដ្ឋកិច្ច ៖ កាលណាមានវិបត្តិសេដ្ឋកិច្ចកើតឡើងនាំឲ្យក្រុមហ៊ុន សហគ្រាស អាជីវកម្ម ត្រូវប្រឈមមុខនិងការក្ស័យធន ព្រោះថាតម្រូវការអតិថិជនមានការធ្លាក់ចុះដែលជាហេតុបណ្តាលឲ្យចំណូលផ្ទាល់ខ្លួន និង ចំណូលក្រុមហ៊ុនធ្លាក់ចុះ។ ដូចនេះក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលមកធនាគារវិញ។

- គ្រោះធម្មជាតិ ៖ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ទឹកជំនន់ ភ្លើងឆេះផ្ទះ និងបាតុភូតធម្មជាតិ នាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងដោយសារតែអាជីវកម្មត្រូវបានផ្អាកដំណើរការ។

### ៣.៤.៧.៣. វិធីសាស្ត្រកាត់បន្ថយហានិភ័យឥណទាន

ដើម្បីគ្រប់គ្រងឥណទានឲ្យមានប្រសិទ្ធភាព អេ អឹម ខេ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាអ្នកផ្តល់ឥណទានមានវិធីសាស្ត្រយ៉ាងហ្មត់ចត់ក្នុងការការពារហានីភ័យនេះដោយសិក្សាទៅលើចំណុចចំណុចចំណុចចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ក. ចំពោះអតិថិជន**

មន្ត្រីឥណទានត្រូវតាមដានឲ្យបានជិតដល់ចំពោះអតិថិជនរបស់ខ្លួន ដោយធ្វើការកំណត់ជាបីដំណាក់កាលដូចជា៖

**១.មុនពេលផ្តល់ឥណទាន :** មន្ត្រីឥណទាន ត្រូវប្រមូលព័ត៌មានអំពីអតិថិជនឲ្យបានច្បាស់

លាស់ដោយធ្វើការស៊ើបសួរព័ត៌មានពីអាជ្ញាធរមានសមត្ថកិច្ច អ្នកជិតខាង ក៏ដូចជាអតិថិជនផ្ទាល់ ទាក់ទងទៅនឹងគោលបំណងសុំខ្ចីឥណទាន ទ្រព្យធានា ចំណូលចំណាយ ស្ថានភាពគ្រួសារជាដើម ហើយធ្វើការវាយតម្លៃលើព័ត៌មាននោះថាតើមានភាពលម្អៀងគ្នាដែរ ឬទេ?

**២. អំឡុងពេលផ្តល់ឥណទាន** : ផ្តល់ព័ត៌មានដែលទាក់ទងនឹងអត្រាការប្រាក់ របៀបសងប្រាក់ រយៈពេលខ្ចី ការផាកពិន័យ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការប្រើប្រាស់សេវាឥណទាន។

**៣. ក្រោយពេលផ្តល់ឥណទាន** : មន្ត្រីឥណទានត្រូវតាមដានអតិថិជនខ្លួនថាតើការធ្វើអាជីវកម្មរបស់គាត់មានការរីកចម្រើន ឬទេ មើលថាទ្រព្យធានារបស់ធានារបស់គាត់មានការលក់ដូរ ឬមានការផ្ទេរកម្មសិទ្ធិដែរទេ ហើយតើគាត់មានការជំពាក់បំណុលថែមទៀតជាមួយគ្រឹះស្ថានផ្សេងទៀត ឬទេ។

**ខ. ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

- ប្រធានសាខាត្រូវពង្រឹង ការអនុវត្តរបស់មន្ត្រីឥណទានក្នុងរបាយការណ៍កម្ចីយឺតយ៉ាវ
- ប្រធានសាខាត្រូវចុះត្រួតពិនិត្យផ្ទាល់ លើស្ថានភាពជាក់ស្តែងរបស់អតិថិជននីមួយៗមុននឹងធ្វើការសម្រេចចិត្ត
- ធ្វើការជ្រើសរើសបុគ្គលិកដែលមានចំណេះដឹងទាក់ទងនឹងឥណទាន
- ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ដាក់ទោសចំពោះបុគ្គលិកដែលសាងកំហុសដដែលៗ
- ធ្វើការលើកទឹកចិត្តបន្ថែមដូចជា ផ្តល់ប្រាក់បន្ថែមលើប្រាក់បៀវត្ស ឬតំឡើងតំណែងដល់បុគ្គលិកណាដែលបំពេញការងារបានល្អ។

**៣.៤.៧.៤. វិធីសាស្ត្រដោះស្រាយបំណុលមានបញ្ហា**

ដំណើរការនៃការដោះស្រាយបំណុលមានបញ្ហា គឺជាដំណាក់កាលមួយដ៏សំខាន់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងផលបត្ររបស់ខ្លួន។ ដូច្នេះរាល់ការយឺយ៉ាវរបស់អតិថិជនគ្រឹះស្ថានត្រូវមានចំណាត់ការ ឬការដោះស្រាយប្រមូលបំណុលយឺតយ៉ាវទាំងនោះត្រឡប់មកវិញ។ ចំណាត់ការរបស់គ្រឹះស្ថាន គឺមានចាប់ពីស្រាល រហូតដល់ករណីធ្ងន់ធ្ងរ គឺអាស្រ័យទៅតាមប្រភេទនៃការយឺតយ៉ាវដែលមានដូចជា៖

ក.ការយឺតយ៉ាវ ចាប់ពី ០ - ៣១ ថ្ងៃ

- ផ្តល់ដំណឹងដល់អតិថិជន
- បើយឺតយ៉ាវ ឬជាទំលាប់ធ្វើការប្រមាន ឬធ្វើការផាកពិន័យ

- ទាក់ទងទៅអ្នកធានា ឬអាជ្ញាធរ ធ្វើការដោះស្រាយ
- ធ្វើកិច្ចសន្យាសងប្រាក់

ខ.ការយឺតយ៉ាវ ចាប់ពី ៣១ - ៩០ ថ្ងៃ

- ឲ្យមន្ត្រីឥណទានចុះទៅសួរបញ្ហាបំណុលជាមួយអតិថិជន
- បើមានការគេចវេសមិនព្រមជួបមន្ត្រីឥណទានអាចទៅរកអាជ្ញាធរ ឬអ្នកធានា
- ត្រូវពឹងពាក់អាជ្ញាធរឲ្យអញ្ជើញអតិថិជនដើម្បីការដោះស្រាយ
- ធ្វើកិច្ចព្រមព្រៀងពេលវេលាសងឲ្យបានជាក់លាក់
- ត្រូវជាកពិន័យទៅតាមកម្រិតស្រាល ឬធ្ងន់តាមស្ថានភាពជាក់ស្តែង

គ. ការយឺតយ៉ាវ ចាប់ពី ៩០ - ១៨០ ថ្ងៃ

- ពិនិត្យមើលជាក់ស្តែងដល់ផ្ទះអតិថិជន
- ទាក់ទងដោយផ្ទាល់ជាមួយអតិថិជនលើបញ្ហាសងប្រាក់
- វាយតម្លៃថាតើអតិថិជនមានលទ្ធភាពសង ឬគ្មាន
- ក្នុងករណីដែលមានការគេចវេសមិនចង់សងប្រាក់ គ្រឹះស្ថានមានសិទ្ធិដាក់ពាក្យបណ្តឹងទៅ អាជ្ញាធរមូលដ្ឋានដើម្បីធ្វើការដោះស្រាយ ឬពិភាក្សាអំពីទ្រព្យធានារបស់អតិថិជន។

ឃ ការយឺតយ៉ាវ ចាប់ពី ១៨០ - ៣៦០ ថ្ងៃ

- គ្រឹះស្ថានធ្វើការប្តឹងទៅដល់តុលាការ ដើម្បីបានសិទ្ធិលក់ទ្រព្យធានាដែលអតិថិជនបានដាក់ធានាក្នុងការខ្ចី។

### ៣.៤.៧.៥. ការវាស់វែងអត្រាហានិភ័យឥណទាន

#### ក. អត្រាហានិភ័យឥណទាន

ហានិភ័យឥណទានមានដូចខាងក្រោម៖

- បាត់បង់ចំណូល
- បែកបាក់គ្រួសារ
- បំណុលច្រើនកន្លែង
- របរមិនទាន់ទាត់
- ផ្លាស់ប្តូរទីលំនៅ

#### ខ. អត្រានៃការសងត្រលប់មកវិញ

ឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា ត្រូវបានវាស់វែងគុណភាពនៃការសងត្រឡប់មកវិញតាមអត្រាដូចមានការគណនាដោយប្រើរូបមន្តៈ

| |
|---|
| អត្រាការសងមកវិញ=សរុបទឹកប្រាក់ដែលត្រូវសងហើយបានសង / សរុបទឹកប្រាក់ដែលត្រូវសងx ១០០ |

**គ. បំណុលលុបចេញពីបញ្ជី**

បំណុលដែលត្រូវលុបចេញពីបញ្ជីរបស់គ្រឹះស្ថានមានដូចជាៈ

- អតិថិជនស្លាប់ដោយមានជំងឺ
- អតិថិជនគ្មានលទ្ធភាព

## ៣.៥. លទ្ធផលឥណទាននៃការស្រាវជ្រាវ

### ៣.៥.១. សមតុល្យឥណទានសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ចាប់ពីឆ្នាំ ២០១៤-២០១៦

តារាងបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញ

| ឥណទាននិងបុរេប្រទានអតិថិជន | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| សមតុល្យឥណទានសរុប-ដុល | ៩៤,៥៧៥,៥១៥ | ១២៥,៨៧២,៣៤៥ | ១៤៨,៣៧៤,៩៦១ |

ដ្យាក្រាមបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញ




តាមតារាងសមតុល្យឥណទានខាងលើយើងឃើញថា នៅឆ្នាំ ២០១៤ គ្រឹះស្ថានបានផ្តល់ឥណទានគិតជាប្រាក់ដុល្លារចំនួន ៩៤,៥៧៥,៥១៥ដុល្លារ ។ បើធៀបនឹងឆ្នាំ ២០១៥ ការផ្តល់ឥណទាននៅតែមានការកើតឡើងរហូតដល់ ១២៥,៨៧២,៣៤៥ដុល្លារ ដូចគ្នានេះដែរ នៅឆ្នាំ២០១៦ គ្រឹះស្ថាននៅតែបង្កើនទំហំឥណទានរបស់ខ្លួនរហូតដល់ ១៤៨,៣៧៤,៩៦១ដុល្លារ។ ទំហំឥណទានដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លាបានបញ្ចេញមានការកើនឡើងជាលំដាប់។

តារាងបង្ហាញពីចំនួនអតិថិជនមានការកើនឡើងជាលំដាប់

| ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|
| ៣៣៤,៨៣៣នាក់ | ៣៣៣,៧១១នាក់ | ៣៤២,៨៤៥នាក់ |

ចំណែកឯចំនួនអតិថិជនវិញ គឺមានការកើនឡើងជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ ចាប់ពីឆ្នាំ ២០១៤ មានអតិថិជនចំនួន ៣៣៤,៨៣៣នាក់ បើយើងប្រៀបធៀបពីឆ្នាំ ២០១៤-២០១៥ ទៅនិងឆ្នាំ ២០១៦ គឺមានការកើនឡើងរហូតដល់ ៣៤២,៨៤៥នាក់ ។




**៣.៥.២. ឥណទានដែលបានលុបចេញពីបញ្ជី**

- គ្មានលទ្ធភាពសងត្រលប់មកវិញ
- អតិថិជនស្លាប់ ឬគ្រោះថ្នាក់

**៣.៦. ការវិភាគ** SWOT

**៣.៦.១. ចំណុចខ្លាំង**

តាមរយៈការសិក្សាស្រាវជ្រាវពីការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេសាខាទឹកថ្លា យើងសង្កេតឃើញថា គ្រឹះស្ថានមានចំណុចខ្លាំងជាច្រើនដែលអាចធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះមានភាពរីកចម្រើន ដែលក្នុងនោះមានដូចជា៖

- បុគ្គលិករបស់ អេ អឹម ខេ មានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីបំរើដល់អតិថិជន
- ការផ្សព្វផ្សាយ
- មានការបែងចែកតំបន់ ដើម្បីងាយស្រួលក្នុងការផ្តល់សេវាទាន់ចិត្តដល់អតិថិជន

- ផលិតផលមានផ្តល់ជូនសម្រាប់គ្រប់ប្រភេទនៃអតិថិជន

**៣.៦.២. ចំណុចខ្សោយ**

ទន្ទឹមនឹងការរីកចម្រើន និងចំណុចខ្លាំងជាច្រើន គ្រឹះស្ថានក៏នៅមានចំណុចខ្សោយមួយចំនួនផងដែរ មានដូចជា៖

- មានភាពយឺតយ៉ាវក្នុងការដោះស្រាយបញ្ហាជូនអតិថិជន
- ប្រព័ន្ធមានស្ថេរភាព
- វប្បធម៌ហានិភ័យ
- គណនេយ្យភាព
- ស្មុកស្មាញ

**៣.៦.៣. ឱកាស**

- ម្ចាស់ភាគហ៊ុនមានការគាំទ្រយ៉ាងខ្លាំង
- សក្តានុពលទីផ្សារធំថ្មីមិនត្រូវបានគេយកមកប្រើប្រាស់
- ជំហានឆ្ពោះទៅមុខនៅលើបច្ចេកវិទ្យា និងការធ្វើផែនការមួយចំនួន
- មានចំនួនអតិថិជនគាំទ្រច្រើន

**៣.៦.៤. ការគំរាមគំហែង**

- នយោបាយ និងពាណិជ្ជកម្ម
- ហានិភ័យឥណទាន និងការលួចលាស់
- ស្មុកស្មាញ
- ការប្រកួតប្រជែងបច្ចេកវិទ្យា App តាមទូរស័ព្ទដៃ

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការចុះកម្មសិក្សាស្រាវជ្រាវ យ៉ាងយកចិត្តទុកដាក់លើផ្នែកទ្រឹស្តី និងការចុះកម្មសិក្សាដោយផ្ទាល់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ក្រោមប្រធានបទស្តីពី " ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យម " យើងខ្ញុំសូមធ្វើការសន្និដ្ឋានថា៖

គោលបំណងនៃការផ្តល់ឥណទានរបស់គ្រឹះស្ថាន គឺចង់ចូលរួមចំនែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ដើម្បីជួយលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋ ឲ្យកាន់តែប្រសើរ ជាពិសេសប្រជាពលរដ្ឋក្រីក្រដែលមានបំណងចង់អភិវឌ្ឍស្ថានភាពគ្រួសាររបស់ខ្លួន។ ចំណែកឯដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថាន ត្រូវបានកំណត់ជាជំហានៗ ស្របទៅតាមបទដ្ឋានអង្គភាព ដោយមានភ្នាក់ងារចុះវាយតម្លៃយ៉ាងម៉ត់ចត់ មុននឹងធ្វើការទំលាក់ទុន។ រីឯការសងត្រលប់មកវិញរបស់អតិថិជន គ្រឹះស្ថានទទួលបានគួរជាទីពេញចិត្តបំផុត ព្រោះរាល់ឥណទានដែលបានផ្តល់ដល់អតិថិជនត្រូវប្រមូលមកវិញទទួលបានពី ៩៨% ទៅជាង ៩៩% គឺស្មើរតែ ១០០%ទៅហើយ។ ជាមួយគ្នានេះដែរ គ្រឹះស្ថានទទួលបានការគាំទ្រយ៉ាងខ្លាំង ពីសំណាក់អតិថិជនទាំងឡាយ មិនថាអតិថិជនចាស់ រឺ ថ្មី ព្រោះយើងសង្កេតឃើញថា ចំនួនអតិថិជនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំហើយអត្រាការប្រាក់មានកំរិតសមរម្យដែលអាចឲ្យអតិថិជនទទួលយកបាន និងអាចប្រកួតប្រជែងជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗទៀត។

ទាំងអស់នេះហើយបានបញ្ជាក់ឲ្យឃើញថា ការគ្រប់គ្រងឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ពិតជាមានលក្ខណៈល្អប្រសើរ គឺការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គួរជាទីពេញចិត្តក្រៃលែង។ ម្យ៉ាងវិញទៀតគ្រឹះស្ថានមានយុទ្ធសាស្ត្រល្អៗក្នុងការផ្តល់ឥណទាន ដែលធ្វើឲ្យគ្រឹះស្ថានទទួលបានការពេញចិត្ត និង គាំទ្រយ៉ាងពេញទំហឹងពីបណ្តាអតិថិជនទាំងឡាយ ។ មួយវិញទៀត ការគ្រប់គ្រងឥណទានខ្នាតតូច និង ខ្នាតមធ្យមពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាទឹកថ្លា ទទួលបានជោគជ័យទៅបានអាស្រ័យទៅលើអ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់ដែលមានការសហការគ្នាបានយ៉ាងល្អ និងធ្វើឲ្យគ្រឹះស្ថានកាន់តែមានភាពរីកចម្រើននៅពេលបច្ចុប្បន្ន និងទៅអនាគត ហើយក៏ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានតម្រូវការមូលធន ក៏ដូចជាប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានភាពរីកចម្រើន។

**២ ការផ្តល់អនុសាសន៍**

តាមសេចក្តីសន្និដ្ឋានខាងលើបានបញ្ជាក់ថា ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មានលក្ខណៈល្អប្រសើរ និងមានប្រសិទ្ធភាពគួរជាទីមោទនៈ។ តែទោះបីជាយ៉ាងណាក៏ដោយក៏យើងសង្កេតឃើញមាននូវចំណុចខ្វះខាតមួយចំនួនតូចផងដែរ។ ដូចនេះដើម្បីឲ្យ ការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថាន កាន់តែប្រសើរថែមទៀត និងអាចប្រកួតប្រជែងដណ្តើមទីផ្សារនៅពេលអនាគត ហើយទទួលបានប្រជាប្រិយភាពកាន់តែច្រើនពីអតិថិជន គ្រឹះស្ថានគួរតែបំពេញនូវចំណុចខ្វះខាតទាំងនោះ។ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមចូលរួមផ្តល់មតិយោបល់ខ្លះៗដូចខាងក្រោម៖

- ធ្វើការបណ្តុះបណ្តាល និងហ្វឹកហាត់បន្ថែមទៅលើភ្នាក់ងារឥណទានចំពោះគោលការណ៍ថ្មីៗ ដើម្បីបង្កើនសមត្ថភាពការងាររបស់ខ្លួន
- ធ្វើការផ្សព្វផ្សាយ និងពង្រីកសេវាឥណទានឲ្យបានទូលំទូលាយជាងនេះ ដល់ប្រជាពលរដ្ឋក្នុងតំបន់ ឬសហគមន៍ផ្សេងៗទៀត
- បើកទូលាយនូវទំហំឥណទានតាមសំណើររបស់អតិថិជន ក្នុងករណីពិនិត្យឃើញសមស្របតាមប្រភេទអាជីវកម្ម លទ្ធភាពជាក់ស្តែង ដើម្បីជាជម្រើសដល់អតិថិជនគ្រប់ប្រភេទ និងភាពរីកចម្រើនរបស់គ្រឹះស្ថាន។

# ឯកសារយោង


- http://www.amret.com.kh/amret/index.php/km/2012-08-06-03-28-30/2012-10-01-06-35-24
- Sector highlight: Cambodia Microfinance: Development and Challenges by Mr. Kim Vada, Deputy Director General for National Bank of Cambodia, on March 15-17, 2010 at Dhaka, Bangladesh)
- www.nbc.org.kh/legislation/law_on_banking_and_financial_institutions.php, ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- http://www.nbc.org.kh/economic_research/mfis_reports.php
- ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, <<វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច>>, ទំព័រ ៤៨៤
- ធនាគារជាតិនៃកម្ពុជា, ២០០៨, <<ច្បាប់ក្រមអនុវត្តចំពោះធនាគារ និង ហិរញ្ញវត្ថុ>>, ទំព័រ ៥៥១
- Mr. Long Mamidi.2012-2013, Personal Finance, ទំព័រទី២៥
- ជួន ណាត, ១៩៦៧,"វចនានុក្រមខ្មែរ" ទំព័រ ១៧៦៥
- ភឹម សុបំណង, ២០១១,គ្រប់គ្រងឥណទាន,ទំព័រ ៣
- ម៉ៃ សុខជេដ្ឋា, ២០០៥, "ស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា", ទំព័រ ៤២
- Robert Cole and Lon Mishler,1998 ,Consumer and Business Credit Management International Edition Pag11-12
- ឯម វាសនា ឆ្នាំ២០១១,ការគ្រប់គ្រងឥណទាន,ទំព័រពី ១០-១៤
- ឯក វាសនា ឆ្នាំ២០១១, ការគ្រប់គ្រងឥណទាន, ទំព័រទី ២៩-៣៤
- ង្វួន ហេង ឆ្នាំ២០១៤, ធនាគារ និងរូបិយវត្ថុ ទំព័រ៥៥
- សុខ ចំរើន និង ឡេង សុភក្ត្រ ឆ្នាំ២០១៣,ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ទំព័រ ៥៦-៥៧